**PTI0056**

## សម្ភាសន៍ជាមួយឈ្មោះ ពេន ហន ភេទប្រុស អាយុ៥៣ឆ្នាំ
## មុខងារជំនាន់ខ្មែរក្រហម«យោធា»
## ស្រុកកំណើតនៅភូមិបឹងព្រៃ ឃុំស្ទឹង ស្រុកបាណន់ ខេត្តបាត់ដំបង
## រស់នៅភូមិស្ទឹងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់
## ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១១
## សម្ភាសន៍ដោយៈ សុខ វណ្ណៈ
## ០១:១០:៤៧
## ៣៥ទំព័រ

វណ្ណៈ: ចឹងថ្ងៃហ្នឹងថ្ងៃទី១៩ ខែ៥ឆ្នាំ២០១១ ខ្ញុំឈ្មោះ សុខ វណ្ណៈមកពីអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជាហើយខ្ញុំមកដល់ភូមិឃុំរបស់ពូក៏ដោយសារខ្ញុំចឹងដឹងរឿងរ៉ាវទុកជាប្រវត្តិសាស្រ្តដែលមនុស្សជំនាន់ពូធ្លាប់ឆ្លងកាត់សម័យលន់ នល់ ឆ្លងកាត់សម័យសង្គមរាស្រ្តនិយមជំនាន់ប៉ុល ពតមករហូតជួបការលំបាកយ៉ាងម៉េច?

ហនៈ បាទ ។

វណ្ណៈ: ហើយតស៊ូមកវាមានលក្ខណៈយ៉ាងម៉េច ពិបាកស្រណុកយ៉ាងម៉េចពូបានដឹងរឿងរ៉ាវការពិតយ៉ាងម៉េចហើយពិបាកថាពិបាកស្រណុកថាស្រណុកដែលយើងបានជួបប្រទះ ។

ហនៈ បាទ ។

វណ្ណៈ: ហើយការដែលខ្ញុំសម្ភាសជាមួយពូហ្នឹងរឿងរ៉ាវទាំងអស់ហ្នឹង យើងទុកឲ្យក្មេងជំនាន់ក្រោយបានដឹងបានព្ធថាប្រទេសពីជំនាន់មួយទៅជំនាន់មួយជួបបញ្ហាចេះមួយៗ ហើយបើសិនជាយើងមិនធ្វើការចងក្រងទុកទេ បើយើងនិយាយតៗក្មេងវាមិនជឿបើយើងមានកម្មវិធីបង្រៀនក្នុងសាលាឬយើងសរសេរឲ្យបានដឹងច្បាស់លាស់អីក្មេងវាមិនជឿពូ ។

ហនៈ បាទ!មានភស្តុតាងពិតប្រាកដ ។

វណ្ណៈ: បាទ!ចឹងបានវាជឿបើយើងមិនកត់ត្រាទុកទេ វាមិនជឿទេ កាលណានិយាយតៗថាសម័យគេសម្លាប់មនុស្សពិតជាវាថា ហេតុមិនតដៃ គេបង្អត់បាយយើងហេតុមិនតវ៉ាអីចឹងណាពូ ។

ហនៈ ចឹងហើយបើយើងគ្មានកំណត់ហេតុគ្មានចងក្រងទុកពាក្យអ្វីមួយទេ ក្មេងឥឡូវនេះខួរក្បាលវាមិនមែនធម្មតាទេ ។

វណ្ណៈ	បាទ ។

ហានៈ	វាមិនជឿយើងទេ ។

វណ្ណៈ	បាទ! ព្រោះវាកើតមកមានហូបអីស្រាប់ចឹង?

ហានៈ	បាទ! ម៉ែវាប្រាប់ទៅថាម៉ែវាកុហក់ចេះចុះទៀត ខ្ញុំកើតមកមិនដែលឃើញមានស្អីទេ ការពិតឪហ្នឹងអាក្រក់ល្អល្ងឹងដូចត់យ៉ាងម៉េចដឹងអស់ ។

វណ្ណៈ	ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះ ពូ ពូឈ្មោះអីដែរ?

ហានៈ	ខ្ញុំពេន ហាន ។

វណ្ណៈ	ពូអាយុប៉ុន្មានហើយ?

ហានៈ	ខ្ញុំ៥៣ហើយ ។

វណ្ណៈ	ប្រពន្ធពូឈ្មោះអីដែរ?

ហានៈ	ឈ្មោះ យ៉ា រ៉េត ។

វណ្ណៈ	គាត់អាយុប៉ុន្មានហើយ?

ហានៈ	គាត់អាយុ៥១ហើយ៥២គាត់ប្អូនខ្ញុំមួយឆ្នាំ ។

វណ្ណៈ	ចឹង៥២?

ហានៈ	បាទ ។

វណ្ណៈ	ចឹងសព្វថ្ងៃមានកូនចៅប៉ុន្មានហើយ?

ហានៈ	មានបី ។

វណ្ណៈ	មានបីនាក់ប្រុសប៉ុន្មានដែរ?

ហានៈ	មានប្រុសពីរ ។

វណ្ណៈ	បានការងារធ្វើខ្លះហើយឬនៅឬមានគ្រួសារហើយនៅ?

ហានៈ	មានហើយអាបងគេមានមួយគ្រួ ។

វណ្ណៈ	ចឹង?

ហានៈ	បាទ! ហើយអាបន្ទាប់អាបងហ្នឹងរៀនធ្វើជាងម៉ូតូនៅយើងផ្សារប្រម៉ោយយើងនេះ ។

វណ្ណៈ	ចឹងខ្ញុំចង់ស្គាល់ឪពុកពូ ឪពុកបង្កើតពូឈ្មោះអី?

ហានៈ	ឪពុកខ្ញុំបង្កើតឈ្មោះ ពេនហ្នឹងហើយ ។

វណ្ណៈ	ជីតាគាត់ឈ្មោះ អី?

ហានៈ	ជីតាខ្ញុំឈ្មោះ ហ៊ុន ។

វណ្ណៈ ចឹងម្ដាយពូឈ្មោះអី?

ហានៈ ត្រកូលគាត់ឈ្មោះ សែត ហាវ ។

វណ្ណៈ ចឹងគាត់ទាំងពីរសព្វថ្ងៃ?

ហានៈ គាត់ស្លាប់មួយហើយ ។

វណ្ណៈ ស្លាប់ក្រោយ៧៩ឬស្លាប់ពេលណា?

ហានៈ ស្លាប់តាំងពីយើងមុនរដ្ឋប្រហារលន់ នល់នោះ ។

វណ្ណៈ ចឹងគាត់ស្លាប់យូរហើយ?

ហានៈ បាទ!យូរហើយ ។

វណ្ណៈ ឪពុក?

ហានៈ បាទ ។

វណ្ណៈ ចឹងម្ដាយ?

ហានៈ ម្ដាយខ្ញុំនៅទាល់រាល់ថ្ងៃហ្នឹង ។

វណ្ណៈ ចឹងឪពុកស្លាប់មុនរដ្ឋប្រហា?

ហានៈ បាទ ។

វណ្ណៈ ចឹងភូមិកំណើតពូ ពូកើតនៅភូមិអីទៅ?

ហានៈ ភូមិបឹងព្រៃ ។

វណ្ណៈ ឃុំ?

ហានៈ ឃុំស្ទឹង ។

វណ្ណៈ ស្រុក?

ហានៈ ស្រុកបាណន់ ។

វណ្ណៈ ខេត្តបាត់ដំបង?

ហានៈ បាទ ។

វណ្ណៈ ឥឡូវគេហៅភូមិអីភូមិហ្នឹង?

ហានៈ ភូមិបឹងព្រៃដែរ ភូមិនេះ ។

វណ្ណៈ បាទ!ភូមិសព្វថ្ងៃនេះ?

ហានៈ ពីមុនគេហៅពាមប្រុស ឥឡូវគេនិយមហៅជាទូទៅស្ទឹងថ្មី ។

វណ្ណៈ ឃុំ?

ហានៈ យុំប្រម៉ោយ ។

វណ្ណៈ ស្រុកវាលវែងពូ?

ហានៈ ស្រុកវាលវែង ។

វណ្ណៈ ខេត្តពោធិ៍សាត់ពូ?

ហានៈ ខេត្តពោធិសាត៍ ។

វណ្ណៈ កាលពីតូចពូរៀនបានថ្នាក់ណាដែលកាលពីតូច?

ហានៈ ពីតូចខ្ញុំរៀនបានតែមួយអាទិត្យ ក្រោយមកតាមឪខ្ញុំរហូតមិនដែលបានរៀនទេ មិនដែលបានចូលសាលាទេ ។

វណ្ណៈ ចឹងរៀនបានតែមួយអាទិត្យ?

ហានៈ ខ្ញុំរៀនពីសង្គមហ្នឹងដែរ រៀនបានតែបីថ្ងៃរៀនបានតែមួយអាទិត្យ ។

វណ្ណៈ អត់បានរៀនច្រើនទេ?

ហានៈ អត់បានរៀនចេះជ្រៅជ្រះអីទេ ។

វណ្ណៈ ចឹងរៀនបានតែមួយអាទិត្យទេ?

ហានៈ បាទ!ឪខ្ញុំគាត់ទៅព្រៃតាមគាត់តែរហូតហ្នឹង ។

វណ្ណៈ ចឹងពូរៀបរាប់មើលថាហេតុអីបានជាពូមិនបានរៀន មកពីបញ្ហាអី?

ហានៈ វាមិនជាបញ្ហាម៉ែឪវាមិនមែនជាទីទាល់ក្រប៉ុន្មានទេ តាមពិតទៅបងប្អូនខ្ញុំចេះតែបែកគ្នាទៅសុទ្ធតែអ្នកតស៊ូដល់ចឹងទៅមួយតាមព្រៃចឹងទៅគេដេញបាញ់ទៅ ទៅដេកព្រៃដេកអីទៅចឹងយើងរៀនមិនបានច្បាស់លាស់ ។

វណ្ណៈ បាទ ។

ហានៈ ហើយក៏តាមឪទៅឪយកតាមគាត់ទៅតាំងពីតូចៗចឹងទៅ ។

វណ្ណៈ ចឹងមុនឪពុកពូស្លាប់ហ្នឹងពូមានបងប្អូនបង្កើតប៉ុន្មាននាក់?

ហានៈ មាន៧នាក់ ។

វណ្ណៈ ច្រើនដែរ?

ហានៈ បាទ ។

វណ្ណៈ ចឹងប្រុសប៉ុន្មានស្រីប៉ុន្មាន?

ហានៈ ប្រុសពីរស្រីប្អូនអែ ។

វណ្ណៈ ស្រីប្រាំចឹង?

ហនៈ ស្រី៥ ។

វណ្ណៈ ចឹងមានប្រុសតែពីរ?

ហនៈ បាទ ។

វណ្ណៈ ចឹងកាលទៅតាមព្រៃហ្នឹងមានមូលហេតុអីបានទៅព្រៃហ្នឹងហើយក្នុងឆ្នាំណាដែរ ជំនាន់សម្តេចសី ហនុឬមួយជំនាន់លន់ នល់?

ហនៈ ខ្ញុំដឹងតាមគាត់ហ្នឹងតាំងពីឆ្នាំ៧០មក ខ្ញុំចាំខ្ញុំចងក្រងទុក ។

វណ្ណៈ បាទ ។

ហនៈ ខ្ញុំដឹងថាតាមឪពីតូចមកខ្ញុំដឹងថាទៅនេះទៅនោះ ខ្ញុំកាលហ្នឹងវានៅក្មេងៗពេកខ្ញុំមិនដឹងជាឆ្នាំណាអីឆ្នាំណាខ្ញុំចងចាំក្រោយមកបានខ្ញុំចាំច្បាស់ក្នុងឆ្នាំ៧០ហ្នឹងរដ្ឋប្រហារហើយ ។

វណ្ណៈ ចឹងកាលហ្នឹងសម្តេចសី ហនុលែងបានចូលស្រុកហើយ?

ហនៈ លែងបានចូលស្រុកហើយ ។

វណ្ណៈ ចឹងកាលហ្នឹងមានលោកសេនាប្រមុខលន់ នល់មែនទេ?

ហនៈ បាទ ។

វណ្ណៈ ចឹងតាមទៅព្រៃហ្នឹងមុនរដ្ឋប្រហាហ្នឹងទៀត?

ហនៈ មុនរដ្ឋប្រហាទៀតជំនាន់ហ្នឹងគេហៅខ្មែរ“ស”ខ្មែរ“ខ្មៅ”អីម៉េចជំនាន់ហ្នឹង ធ្មេញខ្មៅអីណា ។

វណ្ណៈ ចឹង?

ហនៈ តាមដែលខ្ញុំដឹង ។

វណ្ណៈ បាទ ។

ហនៈ ហ្នឹងដឹងមិនមែនជាទ្រុងទ្រាយធំគ្រាន់តែចង់ចាំ មិនបានចងក្រងទុកអីអត់ទេ ដឹងដោយដុំកន្លែងណាយើងអាចចាំបានចាំទៅ កន្លែងណាយើងអត់ដឹងអត់ ។

វណ្ណៈ បាទ!ចឹងនៅពេលមានរដ្ឋប្រហាឆ្នាំ៧០ហ្នឹង ចូលព្រៃអីហ្នឹងពូនៅជាមួយឪពុកម្តាយដែលឬមួយយ៉ាងម៉េចឬមួយពូចូលព្រៃដែរ?

ហនៈ ពេលហ្នឹងខ្ញុំបែកចេញពីគាត់ហើយ ខ្ញុំទៅតាមកងតាមកំលាំងមេបញ្ជាការកាន់កាំភ្លើងហើយហ្នឹងនោះ ។

វណ្ណៈ ចឹងរដ្ឋប្រហាហើយពីកាន់កាំភ្លើងហើយ?

ហនៈ បាទ ។

វណ្ណៈ ចឹងពូអាយុប្រហែលជាប៉ុន្មានទៅបើតាមពូគិតមើល?

ហន:	ខ្ញុំកាលហ្នឹងខ្ញុំអាយុ១៨ទៅ១៩ហើយ ។

វណ្ណៈ:	ចឹងកាលហ្នឹងអាយុ១៩ឆ្នាំចូលធ្វើជាយោធាតែម្តង?

ហន:	បាទ!កាំភ្លើងស្ពាយមិនទាន់ផុតពីដីផងកាលហ្នឹង ។

វណ្ណៈ:	ចឹងពូកាលហ្នឹងគិតឃើញយ៉ាងម៉េចដែលបានជាពូចូលបំរើចលនាវៃជាមួយលន់ នល់ទឹក ឃើញឈឺចាប់ឬមួយយ៉ាងម៉េច?

ហន:	អត់មានអារម្មណ៍ឈឺចាប់យ៉ាងម៉េចទេ យើងគិតវាមិនដល់កាលតស៊ូហ្នឹង តស៊ូមិនបានដុស ចេញពីគំនិតខ្លួនឯងគិតឃើញយ៉ាងម៉េចអីយ៉ាងម៉េច ដឹងថាគេទៅ ទៅហ្នឹងគេដែរ ។

វណ្ណៈ:	ចឹងទៅតាមគេទេ?

ហន:	ទៅតាមគេឯង ។

វណ្ណៈ:	គេអត់មានបង្ខំយើងដែរ?

ហន:	គេអត់មានបង្ខំយើងទេ យើងចេះតែទៅគេឯងទៅចង់សប្បាយចឹងបានយើងគិតវាមិនដល់ និងការតស៊ូ មេបញ្ជាការខ្ញុំថាឯងទៅផ្ទះវិញទៅឯងនៅតូចៗចឹង ឯងតូចជាងគេណាស់ទៅ ម៉ែឪវិញទៅ ខ្ញុំថាខ្ញុំអត់ទៅទេ ខ្ញុំទៅដែលហើយ គាត់ថាបើឯងទៅក៏ទៅទៀតចឹង ។

វណ្ណៈ:	ចឹងគាត់ឃើញតូចៗគាត់ចង់ដេញមកផ្ទះវិញដែរ?

ហន:	បាទ ។

វណ្ណៈ:	ចឹងកាលដែលពូចូលដំបូងហ្នឹងពូចូលនៅម្តុំណា?

ហន:	ខ្ញុំចូលដំបូងខ្ញុំចូលនៅប៉ៃលិននោះ ។

វណ្ណៈ:	យ៉ាងម៉េចបានចូលនៅប៉ៃលិនវិញ?

ហន:	ខ្ញុំមុនសញ្ញាខ្ញុំខាងហ្នឹង ។

វណ្ណៈ:	ស្រែងពូនៅបាត់ដំបងយ៉ាងម៉េចបានជាទៅប៉ៃលិនវិញ?

ហន:	ខ្ញុំរត់ទៅខាងប៉ៃលិនវិញ "អ្នកជិតខាងនិយាយថា បាត់ដំបងប៉ៃលិនហ្នឹងហើយ" ។

វណ្ណៈ:	កាលហ្នឹងអ្នកនាំចូលពីណាគេ?

ហន:	អត់មានអ្នកនាំទេ ជំនាន់ហ្នឹងនោះ ភ័យចេះតែឃើញគេទៅ ទៅគេឯងទៅ ។

វណ្ណៈ:	ចឹងនៅពេលចូលទៅដល់ក្នុងព្រៃគេមានបង្កើតជាកងវរៈកងពលអីយ៉ាងម៉េចឬមិនទាន់ បង្កើតទេកាលហ្នឹង?

ហន:	មានក្បួនខ្នាតមានក្រុមមានផ្ទះសំបែងអីគេ ស្នាក់តាមព្រៃមានហែរមានជាក្រុមជាកងអីមាន ជាដុំធំតិចតូចអីដែរ ។ មានមួយក្រុម១០នាក់២០នាក់ទៅតាមធនធានដែលគេបង្កើតបាន ។

វណ្ណៈ   ចឹងកាលហ្នឹងគេឲ្យពូស្លៀកពាក់ខោអាវរបៀបយ៉ាងម៉េចទៅ ខោអាវខ្មៅឬខោអាវអីដែរ?

ហានៈ   កាលហ្នឹងខោអាវយើងមិនមែនខោអាវខ្មៅហើយក៏មិនមែនខោអាវអាចម៍សេះដែរ ខោអាវហ្នឹងខោអាវពណ៌ស្លឹកឈើ ។

វណ្ណៈ   ចឹងខោអាវពណ៌ស្លឹកឈើ?

ហានៈ   បាទ ។

វណ្ណៈ   ចឹងខោអាវនិងសម្ភារដែលយកឧបម្ភហ្នឹងពូគិតថាប្រទេសខាងណាជាអ្នកឧបម្ភឲ្យកាលហ្នឹង ពូមានបានដឹងទេមានពុគេនិយាយទេ?

ហានៈ   កាលហ្នឹងចិន ។

វណ្ណៈ   ចិន?

ហានៈ   បាទ ។

វណ្ណៈ   ចឹងកាលហ្នឹងពូឡើងវៃចឹង ពូមានការតក់ស្លុតពេលពេលវៃគ្នាជាមួយទាហានលន់ នល់ ហ្នឹងពូមានឃើញសកម្មភាពពេលវៃទៅមានជួបអីខ្លះ?

ហានៈ   អត់មានតក់ស្លុតអត់មានភ័យអីផងមានគិតតែសប្បាយ គេថាឲ្យឡើងៗហ្នឹងគេទៅបាញ់គេទៅ ឃើញគេបាញ់ដូងដួលខ្ពកងាប់នៅមុខចឹងទៅទៀតទៅគ្រាប់កំពង់តែផ្ទុះហ្នឹង ។

វណ្ណៈ   ចឹងអត់មានភ័យខ្លាចទេ?

ហានៈ   អត់មានភ័យខ្លាចទេ អត់មាននឹកឃើញថារស់មិនរស់អីអត់មាននឹកឃើញអត់មានគិតអី គិតថាផ្ទុះអាវុធដូងផាំងៗគិតតែពីសប្បាយទៅ បាញ់ប្រូងប្រាំងចឹងទៅ ។

វណ្ណៈ   ចឹងបានគេថាក្មេងឈាមរាវចឹងមែនឬយ៉ាងម៉េច?

ហានៈ   បាទ ។

វណ្ណៈ   ចឹងកាលហ្នឹងអត់មានចេះពិចារណា?

ហានៈ   អត់មានពិចារណាថាងាប់ អត់ជួបម៉ែជួបឪជួបបងជួបប្អូនវិញអត់មានគិតឃើញទៅចឹងៗវិញ គិតថាគេឡើងៗដែរ គេបាញ់ៗដែរ ។

វណ្ណៈ   ចឹងទោះបីជាឃើញងាប់នៅហ្នឹងមុខក៏ដោយ?

ហានៈ   ទោះបីឃើញនៅមុខក៏ដោយ ។

វណ្ណៈ   ចឹងកាលហ្នឹងទាហាន លន់ នល់ដែលចាប់បានទាហានខ្មែរក្រហម ហើយទាហានខ្មែរក្រហមមានចាប់បានទាហានលន់ នល់ទេ កាលហ្នឹង?

ហានៈ   មានតើចាប់បាន ចាប់បានទៅវិញទៅមក ។

វណ្ណៈ ចឹងបើតាមមើលឯកសារឃើញមានធ្វើទារុណកម្មគ្នាទៅវិញទៅមកច្រើនណាស់?

ហានៈ ទៅវិញទៅមក ។

វណ្ណៈ ចឹងនៅពេលដែលចាប់បានមកហ្នឹងមានធ្វើទារុណកម្មមែនឬមួយយ៉ាងម៉េច?

ហានៈ វាមានខ្វះដូនអីស្វែររកខ្មែរគិញបង្កប់អីហ្នឹង "សេ អ៊ី អា"បង្កប់អីហ្នឹងនៅត្រង់ណាអីត្រង់ណាពីណាជាអ្នកបញ្ជាអីមកចឹងទៅធ្វើទារុណកម្មតាមមនុស្ស ពេលចាប់បានហ្នឹង ។

វណ្ណៈ ចឹងខាងលន់ នល់ក៏មានចាប់បានយើងដែរ ហើយយើងក៏មានចាប់បានខាងលន់ នល់ដែរ?

ហានៈ បាទ ។

វណ្ណៈ ចឹងកាលហ្នឹងពូមានដឹងថា ហេតុអីបានជាកំលាំងខ្មែរក្រហមមានចលនាខ្លាំងរហូតទទួលបានជ័យជំនះចូលដល់ភ្នំពេញអីហ្នឹង ពូថាមកពីកំលាំងយ៉ាងម៉េចដែរឬមានទឹកចិត្តក្លាហានឬមានអ្នកនៅពីក្រោយនិងមាំទាំឬមួយយ៉ាងម៉េចបើតាមពូស្មាន?

ហានៈ តាមខ្ញុំគិតអត់មានពីណាបង្ហុំអត់មានពីណាពង្រឹងឲ្យមាំទាំពីក្រោយអត់ទេ វាគ្រាន់តែថា ការតស៊ូហ្នឹងវាមានអាវុធមានប្រដាប់ប្រដាគ្រប់គ្រាន់ ។

វណ្ណៈ ចឹង?

ហានៈ បាទ!មានគ្រឿងផ្ទុះអីគ្រប់គ្រាន់បាយចុកតាំងពីម្ហូបហូបចុកឡើងទៅអត់បាច់ពិបាក ។

វណ្ណៈ បាទ ។

ហានៈ ចឹងពេលហ្នឹងមនុស្សមានទឹកចិត្តធ្វើ អត់មានបងប្អូនណាទៅបង្ហុំបងប្អូនណាអត់ទេ អត់មានថាឯងមិនទៅយកទៅដាក់គុកដាក់ច្រវ៉ាក់ដូចសម័យយើងនេះអត់ទេ អត់មានដូចទាហានយើងឥឡូវនេះ និយាយត្រង់នេះ ។

វណ្ណៈ បាទ ។

ហានៈ អត់មានថាឯងមិនទៅក៏អត់មានអីដែរ ឯងនៅផ្ទះក៏នៅទៅ អ្នកចង់ទៅៗ ។

វណ្ណៈ ចឹងកាលពូចូលទៅខាងប៉ៃលិនហ្នឹង អ្នកគ្រប់គ្រងពូដូចថាប្រធានកងពលឬប្រធានវរៈសេនាតូចសេនាធំអីពូមានស្គាល់ទេ?

ហានៈ ស្គាល់ ។

វណ្ណៈ ឈ្មោះអីគេ ប្រធានវរៈសេនាតូច?

ហានៈ ប្រធានវរៈសេនាតូចឈ្មោះអីគិតមើលសិន ឈ្មោះបងទ័ព ។

វណ្ណៈ ឈ្មោះ ទ័ព?

ហានៈ បាទ ។

វណ្ណៈ	ចឹងឥឡូវគាត់មិនដឹងជានៅណា?

ហនៈ	ឥឡូវគាត់នៅតើ ។

វណ្ណៈ	គាត់នៅណាចឹង?

ហនៈ	នៅប៉ៃលិន ។

វណ្ណៈ	នៅប៉ៃលិន?

ហនៈ	បាទ ។

វណ្ណៈ	មិនដឹងថាឈ្មោះអីទ័ពទេ?

ហនៈ	អត់ដឹង ។

វណ្ណៈ	ចឹងមានស្គាល់ប្រធានកងពលមានស្គាល់ទេ?

ហនៈ	អ៊ី ឈានយើងនេះ ។

វណ្ណៈ	អត់ទេ ជំនាន់ខ្មែរក្រហមជំនាន់ដឹកនាំឆ្នាំ៧០ ជំនាន់៧២-៧៣រហូត៧៥ហ្នឹង?

ហនៈ	ឈ្មោះ ដៃ វណ្ណៈ ។

វណ្ណៈ	ហ្នឹងប្រធានចលនាហ្នឹង?

ហនៈ	ប្រធានកងពលហ្នឹង ។

វណ្ណៈ	គាត់មិនដឹងជានៅណា?

ហនៈ	ហ្នឹងអត់ដឹងទេបាត់ខ្លួនបាត់ហើយក៏មិនដឹង ។

វណ្ណៈ	ឈ្មោះ ដៃ វណ្ណៈ?

ហនៈ	បាទ ។

វណ្ណៈ	កាលហ្នឹងកងពលប៉ុន្មានពូកាលហ្នឹង?

ហនៈ	កងពល១៥ ។

វណ្ណៈ	កងពល១៥?

ហនៈ	បាទ ។

វណ្ណៈ	ចឹងពូនៅវរៈសេនាតូចលេខប៉ុន្មាន?

ហនៈ	វរៈសេនាតូច១៨ ។

វណ្ណៈ	វរៈសេនាធំ?

ហនៈ	វរៈសេនាធំ៧១ ។

វណ្ណៈ	ចឹងក្នុងមួយវរៈសេនាធំវាមានប៉ុន្មានវរៈសេនាតូច?

ហនៈ	វាមាន៦វរៈសេនាតូច អ!មានបីវរៈ ។

វណ្ណៈ	មានបី?

ហនៈ	ហ្នឹងហើយមានបីវរៈសេនាតូច ។

វណ្ណៈ	ចឹងមានបីតៗគ្នា?

ហនៈ	បាទ!មានបីតៗគ្នាមាន៦វរៈបានមួយវរៈសេនាធំ«អ្នកជិតខាងនិយាយថាកងវរយហ្នឹងមានបីកងហាមានបី«គ»ម៉ាកងវរយធំហើយកងពលមួយវាមានកងបីវរៈតូចក្នុងមួយក្រុមមានគ្នា១២នាក់» ។

វណ្ណៈ	ចឹងពូមានមុខសញ្ញានៅក្រុងប៉ៃលិនហ្នឹងពូមានមុខសញ្ញាវៃចូលក្រុងបាត់ដំបងមែនទេ?

ហនៈ	សំដៅមកបាត់ដំបងហ្នឹងកាលហ្នឹង ។

វណ្ណៈ	ចឹងកាល៧៥ ថ្ងៃ១៧តាមពិត ថ្ងៃ១៧មេសាឆ្នាំ៧៥ខ្មែរក្រហមវៃបានភ្នំពេញហើយ ខាងបាត់ដំបងវៃបានដំណាលគ្នាឬមួយក្រោយឬមួយមុន ពូចាំបានទេ ៧៥ហ្នឹងថ្ងៃ១៧មេសាខ្មែរក្រហមវៃសឹងថាបានទូទាំងប្រទេសហើយ ទាំងភ្នំពេញអីហ្នឹងតែខ្ញុំចង់ដឹងថាក្រុងហ្នឹងចូលនៅថ្ងៃទី១៧មេសាដែលអត់?

ហនៈ	ចូលថ្ងៃតែមួយ ។

វណ្ណៈ	ចូលថ្ងៃតែមួយ?

ហនៈ	បាទ!កាលហ្នឹងថ្ងៃតែមួយ ព្រោះកាលហ្នឹងគ្រាន់តែពុបែកភ្នំពេញខ្ញុំនេះពុមេៗចលនាទ័ពថាឥឡូវត្រៀមទៅភ្នំពេញបែកហើយ យើងមិនបាច់ទៅណាទេ ។

វណ្ណៈ	ចឹងឡើងទៅបាត់ដំបង?

ហនៈ	ទៅបាត់ដំបងទៅ មកជុំគ្នានៅបាត់ដំបងទាំងអស់គ្នានិងទៅ ។

វណ្ណៈ	ចឹងពូអត់មានឡើងបន្តទៅភ្នំពេញទៀតទេ?

ហនៈ	អត់មានទេ ។

វណ្ណៈ	ចឹងតាំងពីមុនបែកភ្នំពេញតាំងពីចលនាតស៊ូ តើពូគិតថាកងទ័ពទាំងសងខាងហ្នឹងតើមានស្លាប់ច្រើនទេ?

ហនៈ	មានស្លាប់ច្រើនតែយើងមិនដឹងថាមានចំនួនស្លាប់ប៉ុន្មាន ខ្ញុំអត់ដឹងទេ ។

វណ្ណៈ	ចឹងដឹងថាស្លាប់ច្រើន?

ហនៈ	បាទ!ដឹងថាស្លាប់ច្រើន ។

វណ្ណៈ ពូយល់យ៉ាងម៉េចដែរ ពេលដែលសង្គ្រាមយើងខុសពីប្រទេសគេ ប្រទេសគេច្រើនតែវ៉ៃប្រទេសមួយផ្សេងទៀត ប៉ុន្តែសង្គ្រាមយើងដោយសាថាអ្នកនយោបាយធ្វើឡើងហ្នឹងគឺខ្មែរយើងវ៉ៃខ្មែរគ្នាឯងរហូត ហើយក្នុងចិត្តពូ ពូយល់យ៉ាងម៉េចដែលរឿងហ្នឹង ពេលសង្គ្រាមខ្មែរវ៉ៃខ្មែរហ្នឹង?

ហានៈ ខ្មែរវ៉ៃខ្មែរហ្នឹងខ្ញុំយល់ចេះទេ ខ្ញុំយល់ថាដាក់ស្តែងខ្លួនខ្ញុំហើយ ខ្ញុំអ្នកបាញ់ខ្ញុំអ្នកបោះខ្ញុំអ្នកកន្ទ្រាក់មីនកន្ទ្រាក់អីដាក់មីនដាក់អីហើយតាមផ្លូវ ក៏ប៉ុន្តែខ្ញុំនិយាយដាក់ស្តែងដូចជាពីមុនមកយើងនិយាយរបៀបលក្ខណៈតស៊ូដាក់ស្តែង ជួនកាលតាមផ្លូវនេះក៏ខ្ញុំធ្លាប់ធ្វើអន្តរាគមន៍ដែរពេលខាងកំលាំងសម្តេចយើងហ៊ុន សែនរាល់ថ្ងៃហ្នឹងណាស់ ។

វណ្ណៈ បាទ ។

ហានៈ ពេលដែលទាហានខ្មែរយើងដើរមុនហ្នឹង ខ្ញុំអត់មានបាញ់ទេ លក្ខណៈថាអត់បាញ់យ៉ាងម៉េចខ្មែរហ្នឹង ខ្មែរគ្នាឯងអត់បាញ់ទេ ។

វណ្ណៈ បាទ!អាហ្នឹងក្រោយមកទៀត?

ហានៈ បាទ!អាហ្នឹងក្រោយមកទៀត ប៉ុន្តែពីមុនមកចំរុះជាមួយលន់ នល់នោះពីមុនមកគេបាញ់យើង យើងបាញ់គេទៅនិងជួបគ្នាអត់បានទេ ។

វណ្ណៈ ចឹងពូយល់ឃើញថាម៉េចលែសង្គ្រាមខ្មែរវ៉ៃខ្មែរ ពូគិតថាមកពីអ្នកនយោបាយឬមកពីយ៉ាងម៉េចដែលតាមពីគិត ពូអាចយល់បានដល់ទេ?

ហានៈ ខ្ញុំថាពេលហ្នឹងមកពីផ្នែកនយោបាយផងក៏មិនដឹងឬមិនដឹង ខ្ញុំថាមួយមកពីផ្នែកនយោបាយ ។

វណ្ណៈ ចឹងពូគិតថាមកពីនយោបាយ?

ហានៈ មកពីអ្នកនយោបាយចាប់ដល់ឲ្យខ្មែរនិងខ្មែរវ៉ៃគ្នា ។

វណ្ណៈ ចឹងបើពូបានឃើញឯកសារវិញ ពូឃើញថាទាំងទាហានលន់ នល់និងទាហានខ្មែរក្រហមងាប់គដើងគ្នា ងាប់ដូចសន្សមគដូចជាអុសចឹង ខ្ញុំមើលឃើញក្នុងឯកសារ ។

ហានៈ បាទ ។

វណ្ណៈ ងាប់គដូចអុសចឹងដោយសារថាសង្គ្រាម តែឥឡូវយើងក៏ផុតពីសង្គ្រាមដែរ?

ហានៈ បាទ ។

វណ្ណៈ តែឥឡូវនៅមានប្រទេសជិតខាងគេមានបញ្ហាវ៉ៃអុកឡុកមួយប្រ៉ាវៗដែរ ។

ហានៈ បាទ ។

វណ្ណៈ	តែសង្គ្រាមខ្មែរនិងខ្មែរយើងត្រូវបានបញ្ចប់អស់ហើយ ចឹងពូគិតថាទៅមុខទៀតពូគិតថាខ្មែរនិងខ្មែរអាចបង្កមានបញ្ហាវៃគ្នាទៀតទេ បើតាមជំនឿចិត្តរបស់ពូវិញ?

ហានៈ	ខ្ញុំជឿថាអត់មានទេ ។

វណ្ណៈ	អត់មានទេ?

ហានៈ	បាទ!ៗទុកចិត្តថាអត់មានហ្នឹងតែម្តង បើថាប្រទេសខាងក្រៅដីទៃទៀតខ្ញុំមិនអាចកំណត់បានទេ ថ្មីត្បិតតែខ្ញុំដាច់ដើងប៉ុណ្ណឹងគេឲ្យទៅធ្វើ ទៅទៀត ។

វណ្ណៈ	ចឹងពូចង់ទៅទៀត?

ហានៈ	មិនទាន់អស់ទឹកចិត្តទេ អ្នកតស៊ូ ។

វណ្ណៈ	បាទ!ចឹងបើវៃជាមួយសាសន៍ដីទៃនៅមានទឹកចិត្តទៀត?

ហានៈ	បាទ ។

វណ្ណៈ	ចឹងបើខ្មែរនិងខ្មែរចប់ហើយ?

ហានៈ	ខ្មែរនិងខ្មែរអត់ទេ ។

វណ្ណៈ	ចឹងអត់មានពីណាមកឃោសនាដឹកដៃទៅទៀតបានទេ?

ហានៈ	មិនបាច់ទេ ឆ្អែតហើយ ។

វណ្ណៈ	នៅជួបជុំប្រពន្ធកូនវិញ?

ហានៈ	មិនបាច់ទេ ថាយកពេជ្រយកអីណាមកដូរឲ្យទៅវៃខ្មែរនិងខ្មែរទៀតអត់ទេ អត់ទៅទេ ។

វណ្ណៈ	ព្រោះយើងធ្លាប់ឆ្លងកាត់អស់ហើយ?

ហានៈ	បាទ!ធ្លាប់ឆ្លងកាត់ច្រើនហើយ ។

វណ្ណៈ	ចឹងពូពេលចូលដល់ឆ្នាំ១៩៧៥ ពូចូលដល់បាត់ដំបងហ្នឹង តើមានថ្នាក់ណាខ្លះមកប្រាប់ខាងយោធាដែលមានឋានៈតូចតាចហ្នឹង ឲ្យជម្លៀសប្រជាជនចេញអីចឹង ចឹងកាលហ្នឹងយ៉ាងម៉េច កាលជម្លៀសហ្នឹងយ៉ាងម៉េចដែរ?

ហានៈ	ជម្លៀសហ្នឹងខ្មែរក្រហមជាអ្នកជម្លៀសទេជំនាន់ហ្នឹង កាលឆ្នាំ៧៥ហ្នឹងជម្លៀសចេញទៅព្រៃទៅអីតៗទៅទៀត ដល់ហើយក៏យើងជម្លៀសទៀតដែរ ។

វណ្ណៈ	ចឹងកាលហ្នឹងទៅដល់ក្រុងយើងប្រាប់ប្រជាជនថាយ៉ាងម៉េចទៅ?

ហានៈ	កាលហ្នឹងយើងប្រាប់ថាមានយួន កាលហ្នឹងមានយួនចូលកាលឆ្នាំ៧៥មិនចឹង មែនទេអាហ្នឹងមានអ្នកតស៊ូមានអ្នកនានិរតីចូលកាប់សម្លាប់អីណាណីហ្នឹង ។

វណ្ណៈ អាហ្នឹងក្រោយមកទៀត ប៉ុន្តែភ្នាមៗមិនទាន់មានពីណាមកឡូកឡំទេ មុនហ្នឹងដូចថាឆ្នាំ៧០-៧១និង៧២និងអាចកំលាំងខ្មែរក្រហមនៅខាងនិរតី នៅខាងកំពង់ចាមអីគេសហការណ៍គ្នាជាមួយយួនខាងជើងអី ។

ហានៈ បាទ ។

វណ្ណៈ វៀតណាមលន់ នល់ហើយខាងលន់ នល់ពីងខាងយួនធៀវគីយួនខាងត្បូងអីហ្នឹង?

ហានៈ បាទ ។

វណ្ណៈ ពីងដូចគ្នាប៉ុន្តែក្រោយមកឆ្នាំ៧៣ត្រូវបានទាហានខ្មែរក្រហមដេញទាហានយួនធ្វេញខ្មៅទៅស្រុកអស់ហើយ?

ហានៈ ទៅអស់ហើយ ។

វណ្ណៈ ប៉ុន្តែខាងបាត់ដំបងអត់មានសហការវៀតណាមលន់ នល់អត់មានទេ?

ហានៈ អត់មានទេ ។

វណ្ណៈ ចឹងដាច់ដោយឡែក?

ហានៈ ដាច់ដោយឡែក ។

វណ្ណៈ ខ្មែរវៃជាមួយខ្មែរលន់ នល់ដែរ?

ហានៈ បាទ ។

វណ្ណៈ ចឹងនៅពេលដែលដល់ក្រុងចឹងយើងមានប្រាប់ប្រជាជនឲ្យចេញពីរបីថ្ងៃអីចឹងសិនឬមួយក៏យ៉ាងម៉េច?

ហានៈ អត់មានប្រាប់អីផង គាត់ចេញគាត់ភ័យដោយខ្លួនឯង ។

វណ្ណៈ ចឹង?

ហានៈ បាទ!ជួនកាលខ្ញុំដល់ភូមិហ្នឹងស្ងាត់ភូមិក៏មានដែរ មានអ្នកនៅតាមផ្ទះម្នាក់ពីរនាក់ប្អូនដបគ្រួសារចឹងទៅ គាត់សម្ងំកន្លែងណាសុខបានគាត់សម្ងំទៅ ។

វណ្ណៈ បាទ!ចឹងកាលចប់បែកឆ្នាំ៧៥ហើយចឹង តើគេបែងចែកពូទៅខាងណាទៀត?

ហានៈ ចប់៧៥ហើយហ្នឹងគេបែងចែកខ្ញុំ ឲ្យខ្ញុំទៅប៉ៃលិនវិញហើយ ។

វណ្ណៈ ចឹងទៅប៉ៃលិនវិញ?

ហានៈ បាទ!ទៅប៉ៃលិនហ្នឹងអត់មានបានទៅក្រុងទេ នៅក្នុងព្រៃ ។

វណ្ណៈ ចឹងកាលហ្នឹងគណៈតំបន់ពូស្គាល់ទេកាលហ្នឹង?

ហានៈ គណៈតំបន់ឈ្មោះ វឿន តែមិនដឹងស្អីវឿនទេ ។

វណ្ណៈ	តា រស់ ញឹមទេ ៧៥ខ្មែរក្រហមចូលហើយ?

ហានៈ	តា រស់ ញឹមអី ។

វណ្ណៈ	ចឹងប្រធានភូមិភាគ ពូមានស្គាល់ទេ?

ហានៈ	ខ្ញុំស្គាល់ដូចជាអត់អស់ដែលទេ ។

វណ្ណៈ	ចឹងប្រធានកងពល ៧៥ ហើយគេបញ្ជូនពូទៅប៉ៃលិនវិញ មិនមែនឈ្មោះដៃ វណ្ណៈហ្នឹង?

ហានៈ	បាទ!មិនមែនទេ ។

វណ្ណៈ	ដូពីណាវិញ?

ហានៈ	ក្រោយឡើងមានម្នាក់បញ្ជូនខ្ញុំទៅឈ្មោះ ជា សារឿន ។

វណ្ណៈ	ចឹងជា សារឿនប្រធានកងពលវិញ?

ហានៈ	បាទ ។

វណ្ណៈ	អាហ្នឹងសម័យខ្មែរក្រហមឆ្នាំ៧៥ កាលបញ្ជូនពូទៅហ្នឹង?

ហានៈ	បាទ ។

វណ្ណៈ	យើងមិនទាន់និយាយកាលវៃជាមួយទាហានរដ្ឋកម្ពុជាកាលឆ្នាំ៧៩ទេ?

ហានៈ	យើងវៃភ្នំពេញហើយហ្នឹង ។

វណ្ណៈ	ចង់និយាយបែកភ្នំពេញ៧៥ ?

ហានៈ	បាទ ។

វណ្ណៈ	ចឹង៧៥ពូចូលដល់បាត់ដំបងបានប៉ុន្មានខែបានគេបញ្ជូនពូទៅព្រំដែនវិញ?

ហានៈ	ខ្ញុំនៅបានប្រហែលជាមួយឆ្នាំដែលដឹង ។

វណ្ណៈ	ចឹង?

ហានៈ	បាទ ។

វណ្ណៈ	ចឹងនៅបាត់ដំបងបានមួយឆ្នាំពូ?

ហានៈ	បាទ ។

វណ្ណៈ	ចឹងឆ្នាំ៧៦ពូទៅប៉ៃលិន?

ហានៈ	បាទ ។

វណ្ណៈ	ចឹងទៅប៉ៃលិនអគ្គការឲ្យធ្វើអី កាលហ្នឹងនៅកាន់កាំភ្លើងនៅឡើយឬមួយឈប់ហើយ?

ហានៈ	កាលហ្នឹងនៅកាន់ ។

វណ្ណៈ	កាលហ្នឹងគេឲ្យទៅធ្វើអីកាលហ្នឹង?

ហានៈ	កាលហ្នឹងគេឲ្យទៅព្រៃកឹបៗ នៅព្រៃហ្នឹងទៅ ។

វណ្ណៈ	ការពារព្រំដែន?

ហានៈ	បាទ!ការពារព្រំដែន ។

វណ្ណៈ	ការពារជាមួយថៃការពារកុំឲ្យខ្មែរយើងរត់ទៅឬការពារយ៉ាងម៉េច?

ហានៈ	ទី១កុំឲ្យថៃវារុលទី២ទៀតកុំឲ្យខ្មែរយើងឡើងចុះប្រឬកប្រឬលជាមួយប្រជាជនថៃហ្នឹង កុំឲ្យទៅនៅស្រុកគេទៅ កុំឲ្យគេវាប់សង្កត់អីចឹងឲ្យនៅស្រុកយើង ។

វណ្ណៈ	ចឹងពូនៅហ្នឹងតាំងពី៧៦ដល់៧៩បែកតែម្តងមែនទេ?

ហានៈ	បាទ ។

វណ្ណៈ	ចឹងកាលនៅហ្នឹងកងយោធាដូចពូចឹងមានច្រើនគ្នារាប់រយនាក់ទេ?

ហានៈ	មានច្រើន ពេលហ្នឹងតាមព្រំដែនហ្នឹងមានផ្ទះមានសំបែងនៅតាមភ្នំអត់មាននៅតាមតំបន់វាលរាបទេ យើងនៅលើភ្នំ ។

វណ្ណៈ	តែអត់មានប្រជាជននៅជិតទេ?

ហានៈ	មានប្រជាជនក្នុងគ្រួសារទ័ពហ្នឹងមាន កូនចៅក្មេងរញ៉េរញ៉ៃមានដូចគ្នា ។

វណ្ណៈ	ចឹងគេឲ្យនៅដែរ?

ហានៈ	ឲ្យនៅដែរ ។

វណ្ណៈ	ចឹងអត់មានប្រមូលដាក់សហករណ៍ហូបបាយរួមនោះ?

ហានៈ	ហ្នឹងយើងចុះមកពីព្រំដែនហើយទេ យើងហូបបាយរួមឆ្នាំ៧៥ ។

វណ្ណៈ	បាទ!៧៥ដល់៧៩នេះ?

ហានៈ	បាទ ។

វណ្ណៈ	អាហ្នឹងខ្មែរក្រហមពេញធឹងហើយ?

ហានៈ	ពេញធឹងហើយ ។

វណ្ណៈ	ចឹងពូនៅការពារព្រំដែន?

ហានៈ	បាទ ។

វណ្ណៈ	ពូដោយសារថានៅក្នុងប្រទេសប្រជាជនជួបការលំបាកត្រូវគេសម្លាប់ហូបមិនឆ្អែតអីចឹង ធ្វើឲ្យប្រជាជនមួយចំនួនរត់ទៅព្រំដែនចឹងខាងទាហានពូដែលចាប់បានទេ យោធាខ្មែរក្រហមដែលចាប់បានប្រជាជនទេ?

ហានៈ	ចាប់បានតើ តែអត់មានកាប់សម្លាប់អីទេ ។

វណ្ណៈ  ចាប់បានបញ្ជូនទៅខាងណាវិញ?

ហានៈ  បញ្ជូនទៅព្រំដែនដូចខ្ញុំថា មិញហ្នឹងមានផ្ទះមានសំបែងមានបន្ទាយគេស្នាក់នៅពង្រឹងហ្នឹង ។

វណ្ណៈ  ខ្ញុំខ្លាចពីច្រឡំ ព្រោះខ្មែរក្រហមកាលណាចាប់បានមនុស្សគឺខាងកងទ័ពមិនសម្លាប់មែនតែគេបញ្ជូនមកខាងសហករណ៍វិញ បញ្ជូនមកខាងសហករណ៍វិញ អត់មានទៅព្រំដែនទេ ព្រំដែនយើងនិយាយកាល៧៩ទេអាហ្នឹង ៧៩យើងអាចទៅព្រំដែនអី តែកាលហ្នឹងយើងអត់មានទំនាក់ទំនងជាមួយថៃទេ គឺនៅក្នុងទូទាំងប្រទេសហ្នឹងគឺមានការអត់អាហារតែដោយឡែកខាងយោធាអីមានអីទេ?

ហានៈ  ហ្នឹងហើយខ្ញុំច្រឡំទេ ត្រង់កន្លែងហ្នឹង ពេលទ័ពខ្មែរក្រហមចាប់បានមែន អត់ទាន់បញ្ជូនមកភូមទេ យកទៅដាក់កន្លែងមេបញ្ជាការសិនបានបញ្ជូនយកមកឲ្យខាងសហករណ៍វិញ ។

វណ្ណៈ  ចឹងនៅពេលដែលប្រជាជនទាំងអស់ហ្នឹងមកខាងសហករណ៍ហ្នឹង ពូគិតថាប្រជាជនទាំងអស់ហ្នឹងមានវាសនាអាចរស់បានទេ?

ហានៈ  ខ្ញុំគិតថាពេលទៅចឹងខ្ញុំថាគ្មានវាសនារស់ទេ មានតិចណាស់ ។

វណ្ណៈ  ចឹងចំណែកកងទ័ពនៅតាមព្រំដែនហ្នឹងការហូបចុកមានគ្រប់គ្រាន់ធម្មតា?

ហានៈ  ធម្មតាអត់មានខ្វះខាតអីទេ ។

វណ្ណៈ  ចឹងពូមានឃើញថា ក្រោយពីចាប់តា រស់ ញឹមហើយក្រោយមកទៀតខាងនិរតីមកគ្រប់គ្រងកន្លែងពូមានគេមកចាប់ប្រធានៗមួយចំនួនទេ ឬមួយអត់មានចាប់ទេ?

ហានៈ  ខ្ញុំគ្រាន់តែដឹងតែខ្ញុំមិនបានដឹងថា ចាប់ពីណាខ្លះអីពីណាខ្លះខ្ញុំអត់ដឹងទេ ព្រោះកាលហ្នឹងខ្ញុំនៅក្មេងតូចតាចដែរ ចឹងគេមិនសូវឲ្យដឹងប៉ុន្មានដែលទេ ។

វណ្ណៈ  ចឹងកាលហ្នឹងពូអត់មានឋានៈជាប្រធានអីទេ?

ហានៈ  ខ្ញុំកាលហ្នឹងអត់មានអីទេ ។

វណ្ណៈ  អត់មានអីទេ?

ហានៈ  នៅកូនទាហាន ។

វណ្ណៈ  កាលហ្នឹងជំនាន់ខ្មែរក្រហមកូនទាហានអាចមានវាសនារស់ជាងមេទាហាន?

ហានៈ  បាទ ។

វណ្ណៈ  ព្រោះខ្មែរក្រហមក្រោយមក គោលនយោបាយគេយ៉ាងម៉េចទេ គេចាប់តែមេៗដាក់គុកទួលស្លែងឬយកទៅសម្លាប់ចោល?

ហានៈ  បាទ ។

វណ្ណៈ	ចឹងនៅខាងប៉ៃលិនហ្នឹងប្រធានកងពលពូថាជា សារឿនហ្នឹង?

ហានៈ	បាទ ។

វណ្ណៈ	ចឹងក្រោយមកមានបាត់ខ្លួនទេ ចឹងមានបាត់ខ្លួនក្រោយមកហ្នឹង?

ហានៈ	បាទ ។

វណ្ណៈ	ចឹងក្រោយមកមានចូលពីណាទៀត?

ហានៈ	ក្រោយមកបានចូលបងយន ជ័យ យន ហ្នឹងខ្ញុំនៅជានិរសាគាត់ហើយចូលគាត់ថ្មីហើយ ។

វណ្ណៈ	ចឹងជ័យ យនហ្នឹងមកពីខាងណាវិញ?

ហានៈ	ជ័យ យននិងជាអ្នកតស៊ូជំនាន់ហ្នឹងតែខ្ញុំមិនបានដឹងប្រវត្តិគាត់ទេ ពីដើមមកគាត់តស៊ូជាមួយ
ខ្ញុំនៅហ្នឹងណាស់ ។

វណ្ណៈ	ចឹងគាត់ជាអ្នកបាត់ដំបងដែលមិនមែនមកពីខាងនិរតីទេចឹង?

ហានៈ	អត់ទេ ។

វណ្ណៈ	ចឹងខាងហ្នឹងមានខាងនិរតីទៅគ្រប់គ្រងទេ ក្រុមតា ម៉ុក?

ហានៈ	មានតើ ។

វណ្ណៈ	ពេលក្រុមតា ម៉ុកទៅ គេថាមានចាប់កងវរៈសេនាធំអីចឹងមែនឬមួយអត់ចាប់ទេពូ?

ហានៈ	អត់មានឃើញចាប់ផង ។

វណ្ណៈ	ចឹងអត់មានអីទេ?

ហានៈ	បាទ ។

វណ្ណៈ	ចឹងតា យនហ្នឹងគាត់ជាប្រធានកងពល?

ហានៈ	ប្រធានវរៈខ្ញុំ ។

វណ្ណៈ	ចឹងជ័យ យនហ្នឹងជាប្រធានវរៈទេ?

ហានៈ	បាទ ។

វណ្ណៈ	វរៈសេនាតូចឬវរៈសេនាធំ?

ហានៈ	វរៈសេនាធំ ។

វណ្ណៈ	ចឹងពូជានិរសា?

ហានៈ	បាទ!ខ្ញុំជានិរសាគាត់ ។

វណ្ណៈ	និរសាហ្នឹងរត់សំបុត្រពីណាទៅណា?

ហានៈ	រត់សំបុត្រពីក្រោយមក មកឲ្យកងទ័ពឃើងខាងមុខ ។

វណ្ណៈ ពីក្រោយហ្នឹងសំដៅពីខាងណាវិញ?

ហានៈ យើងចង់និយាយចម្ងាយ យើងចង់និយាយឧទាហរណ៍ថា ដូចថាពីជនបទទៅខេត្តចឹងទៅ ណាស់វាចឹង ។

វណ្ណៈ ចឹងពូរស់នៅក្នុងរយៈពេលបីឆ្នាំហ្នឹង ក្នុងអំឡុងហ្នឹងពូមានដឹងថា មានការសម្លាប់មនុស្ស ហើយប្រជាជនអត់មានអាហារអីពូមានបានដឹងខ្លះៗដែលឬមួយមិនបានដឹងទេ?

ហានៈ ដឹងពេលហ្នឹងដឹងពេញធឹងហើយ ។

វណ្ណៈ យ៉ាងម៉េចបានជាពូដឹង?

ហានៈ ខ្ញុំបានដឹងខ្ញុំបានឃើញរហូតខ្ញុំបានចាប់កំលាំងដែលខិនខូចដើរស៊ីក្តួចស៊ីដំឡូងហ្នឹង ពេលហ្នឹងខ្ញុំចុះប្រឡូកដាក់ស្តែងខ្លួនឯងហើយ ។

វណ្ណៈ ពួកស៊ីក្តួចស៊ីដំឡូងហ្នឹងពួកណាវិញ?

ហានៈ ពួកប្រជាជនយើងគ្នាអ្នកឃ្លានហ្នឹងណាស់ គេគៀបសង្កត់ហូបបាយមិនគ្រប់មិនគ្រាន់ហ្នឹង ដូចបាននិយាយខាងដើមហ្នឹង ។

វណ្ណៈ ពេលចាប់បាននិងយើងបញ្ជូនយកទៅឲ្យពីណាវិញ?

ហានៈ បញ្ជូនយកទៅឲ្យអង្គការ បញ្ជូនយកទៅឲ្យសហករណ៍ទៅក្រោយទៅឲ្យគេកសាងទៅ យើងមិនដឹងគេកសាងយ៉ាងម៉េចៗអីយ៉ាងម៉េចយើងបញ្ជូនឲ្យគេទៅហើយ ។

វណ្ណៈ ចឹងយើងមិនបានដឹងទេ?

ហានៈ បាទ ។

វណ្ណៈ ចឹងកាលហ្នឹងពូដឹងថាប្រជាជនអត់បាយហើយ?

ហានៈ បាទ ។

វណ្ណៈ ចឹងឃើញមនុស្សស្គមឃើញអីចឹង?

ហានៈ បាទ ។

វណ្ណៈ ចឹងមានបានដឹងថាគេវ៉ៃចោលអ្នក១៧មេសាអ្នកភ្នំពេញអី គេវ៉ៃចោលពូមានដឹងទេកាលហ្នឹង?

ហានៈ មាន!ខ្ញុំឃើញហើយបានដាក់ស្តែងដោយខ្លួនឯងទៀត ។

វណ្ណៈ ដាក់ស្តែងយ៉ាងម៉េចទៅ?

ហានៈ បានយាមពេលនោះខ្ញុំជាសន្តិសុខយាមអ្នកមានទោសមានអីហើយ ។

វណ្ណៈ ក្រែងពូនៅការពារព្រំដែនយ៉ាងម៉េចបានជាពូទៅយាមអ្នកទោសវិញ?

ហានៈ ពេលហ្នឹងក្រោយមកខ្ញុំមកដល់ហ្នឹងវិញហើយ ។

វណ្ណៈ យាមនៅសន្តិសុខអីគេ?

ហានៈ កាលហ្នឹងមកយាមនៅបាត់ដំបងនេះ ។

វណ្ណៈ មកយាមនៅសន្តិសុខបាត់ដំបង?

ហានៈ បាទ ។

វណ្ណៈ បាត់ដំបងហ្នឹងមានឈ្មោះអីគេ សន្តិសុខហ្នឹង?

ហានៈ កន្លែងសន្តិសុខហ្នឹងមេបញ្ជាការខ្ញុំហ្នឹងគាត់នៅរាល់ថ្ងៃ ។

វណ្ណៈ កន្លែងសន្តិសុខបាត់ដំបងហ្នឹងគេហៅសន្តិសុខអីគេហ្នឹង?

ហានៈ កាលហ្នឹងគេហៅកន្លែងភូមិស្ពានដែក សន្តិសុខភូមិស្ពានដែក ស្ពានដែកយើងបាត់ដំបងហ្នឹង ជំនាន់យើងនេះហ្នឹងគេហៅភូមិស្ពានដែក ។

វណ្ណៈ ឃើញផ្ទាល់ហ្នឹងឃើញអ្នកទោសតែម្តង?

ហានៈ បាទ! ឃើញអ្នកទោស ។

វណ្ណៈ ចឹងគេយកវ៉ៃចោលឃើញទេ?

ហានៈ ឃើញគេដឹកឡាន ឃើញគេចងទៅមិនដឹងជាគេយកទៅណា មកវិញឃើញតែឡានទទេៗ ។

វណ្ណៈ បាទ ។

ហានៈ គេថាយកទៅកសាងអង្គការយកទៅដាក់កន្លែងថ្មីអីណា សហករណ៍ថ្មីអីណាគេត្រូវការដីក ឬសគល់អីណាណី ។

វណ្ណៈ ចឹងពូយាមនៅហ្នឹងរយៈពេលយូរឆ្នាំដែលឬមួយមិនជាយូរប៉ុន្មានទេ?

ហានៈ ខ្ញុំយាមបានខ្វីដែលទេ ខ្ទង់ប្រហែលជា៦ខែទេ ៦ខែហើយក្រោយឡើងខ្ញុំខុសខ្លួនឯង ។

វណ្ណៈ ខុសយ៉ាងម៉េចទៅ?

ហានៈ ខុសត្រង់ថា ខ្ញុំលួចលែងមនុស្ស ។

វណ្ណៈ ចឹង?

ហានៈ បាទ ។

វណ្ណៈ ចឹងពូហ៊ានលួចលែងមែនអី?

ហានៈ ខ្ញុំលែងមែនខ្ញុំជួយមនុស្សមែន ។

វណ្ណៈ យ៉ាងម៉េចបានជាពូហ៊ានលែងមនុស្ស ពូស្គាល់គ្នា?

ហានៈ	ពេលហ្នឹងមិនស្គាល់គ្នាអីទេ ខ្ញុំឃើញថាគាត់អង្គុយអីទៅអូនអើយក្មួយអើយអីចាស់ហើយអី អីនឹកប្រពន្ធនឹកកូនណាស់ អីសុំបាយហូបខ្លះអីខ្លះមកនឹកឃើញអាណោចអធ្មមជួយគាត់ធ្វើបុណ្យគាត់ក្រោយមកអង្គការដឹងសាច់រឿង ។

វណ្ណៈ	កាលហ្នឹងពូលែងបានប៉ុន្មាននាក់?

ហានៈ	ខ្ញុំលែងមុននិងអង្គការដឹងសាច់រឿងខ្ញុំលែងបានប្រហែលជា៥០នាក់ ហើយប៉ុណ្ណឹងខ្ញុំអត់ស្លាប់ទៀតណាស់ គេអត់យកខ្ញុំទៅសម្លាប់ទៀត ។

វណ្ណៈ	យ៉ាងម៉េចបានជាចឹងពូ ពូមានអ្នកធំជួយពីក្រោយ?

ហានៈ	ខ្ញុំកាលហ្នឹងអត់មានពីណាជួយខ្ញុំទេ តែគ្រាន់ថាពេលដែលខ្ញុំខុសហ្នឹងហើយខ្ញុំបំបាត់ភស្តុតាងខ្ញុំចោលទាំងអស់អត់មានទុកឲ្យនៅទេ ។

វណ្ណៈ	បំបាត់យ៉ាងម៉េចទៅ?

ហានៈ	ខ្ញុំបំបាត់ភស្តុតាងចង់និយាយថា ខ្ញុំមិនឲ្យគេដឹងពូជពង្សវង់ត្រកូលនៅជាមួយគាត់ហ្នឹងពេលហ្នឹង ពេលហ្នឹងគេអត់ចាប់ខ្ញុំទាន់ទេ ពេលហ្នឹងខ្ញុំចេញពីហ្នឹង ខ្ញុំចេញពីនោះហើយក្នុងអង្គការហ្នឹងតែមួយហ្នឹង គ្រាន់តែចេញពីវរៈហ្នឹងទៅវរៈនោះ ។

វណ្ណៈ	ចឹងពេលដែលលែងមនុស្សហើយពូរត់ចេញ?

ហានៈ	ពេលលែងមនុស្សហើយមិនទាន់រត់ចេញភ្លាមទេ រហូតដល់បែកការណ៍អង្គការគេដឹងថាបានលែងមនុស្សមែនបានលែងមនុស្សមែនខ្ញុំរត់ចេញពីហ្នឹង ខ្ញុំរត់ចេញពីហ្នឹងខ្ញុំរកកន្លែងរស់ទៀត ។

វណ្ណៈ	ចឹងអង្គការដឹងបានរត់ រត់ទៅនៅវរៈណាផ្សេង?

ហានៈ	ខ្ញុំរត់ទៅនៅវរៈ២១ ក្នុងកងពលតែមួយទេ ។

វណ្ណៈ	កងពលលេខប៉ុន្មាន?

ហានៈ	កងពលខ្ញុំថាមុនហ្នឹងកងពល១៥ហ្នឹង ។

វណ្ណៈ	ចឹងគេអត់មានតាមស្រាវជ្រាវរកចាប់ពូទេ?

ហានៈ	តាមជួបខ្ញុំស្គាល់ទាំងមនុស្សទៀត យ៉ាងម៉េចគេចាប់ខ្ញុំមិនបាន ។

វណ្ណៈ	យ៉ាងម៉េចបានជាចាប់មិនបាន?

ហានៈ	ខ្ញុំបំបាត់ត្រកូលអត់ឲ្យមានទាំងអស់ ខ្ញុំធ្លាប់ដាក់ត្រកូលខ្ញុំម៉េចៗមានទាំងអស់ ដល់ចឹងខ្ញុំទៅកន្លែងថ្មីហ្នឹងខ្ញុំកែឈ្មោះ កែត្រកូល ទៅដាក់អាណាអាណីផ្សេងទៅ ។

វណ្ណៈ	ចឹងស្រាវជ្រាវដែលតែរកមិនឃើញព្រោះពូដូរឈ្មោះ?

ហានៈ	បាទ ៗ

វណ្ណៈ	ចឹងពេលពូទៅវរៈថ្មីគេអត់មានឆ្ងល់ពូសួរដេញដោលពូថាពូមកពីខាងណាទេ?

ហានៈ	ឆ្ងល់ថាមកពីវរៈណាអីវរៈណាប្រាប់គេត្រង់មែន ប្រាប់ទៅគេរាយការណ៍ទៅវរៈនិងមែន ឈ្មោះៗនេះបានមកថ្ងៃនេះៗចូលធ្វើមានកំលាំងមកថ្មីមួយ មកនៅវរៈខ្ញុំខាងនេះវរៈបង ឯងចេះមួយចេះពីរគេនិយាយត្រង់ច្បាស់ចឹងបណ្តោយ ។

វណ្ណៈ	ចឹងគេនិយាយចឹងហើយម៉េចបានជាគេរកពូមិនឃើញទៀត?

ហានៈ	គេរកឃើញមិនដឹងជាគេធ្វើអីខ្ញុំ គេអត់ចាប់អត់ធ្វើអីខ្ញុំ ។

វណ្ណៈ	ចឹងគេអត់មានចាប់ទេ?

ហានៈ	បាទ ៗ

វណ្ណៈ	ចឹងពូមកនៅវរៈក្រោយហ្នឹងប្រធានពូឈ្មោះអីទៅវរៈ២១ហ្នឹងពូចាំឈ្មោះឬអត់ចាំ?

ហានៈ	ប្រធានវរៈហ្នឹងឈ្មោះ បង អ៊ុច វណ្ណា ។

វណ្ណៈ	ចឹងពូនៅហ្នឹងរហូតដល់បែក៧៩ពេលវៀតណាមចូលតែម្តង?

ហានៈ	បាទ ៗ

វណ្ណៈ	ចឹងខ្ញុំចង់សួរបញ្ជាក់បន្តិចអ្នកទោសគេចាប់នៅបាត់ដំបងហ្នឹង មានអ្នកទោសច្រើនទេនៅហ្នឹង ពូ?

ហានៈ	អ្នកទោសដឹកចូលម្តងខ្ទង់ជា១០០នាក់ ។

វណ្ណៈ	យី!ច្រើនម្ល៉េះ?

ហានៈ	បាទ ៗ

វណ្ណៈ	គុកធំចឹង?

ហានៈ	ធំណាស់ ។

វណ្ណៈ	នៅម្តុំណាស្ពានដែកហ្នឹង?

ហានៈ	វត្តមួយយកទៅធ្វើគុកហើយមិនមែនធម្មតាណា ។

វណ្ណៈ	គេហៅវត្តអី?

ហានៈ	គេហៅវត្តប្រភិត ។

វណ្ណៈ	វត្តប្រភិត?

ហានៈ	បាទ ៗ

វណ្ណៈ	ចឹងមនុស្សនៅហ្នឹងច្រើនដែរ?

ហាន៖ បាទ ។

វណ្ណៈ៖ ចឹងកាលហ្នឹងចូលម្តងៗ៥០ទៅ១០០?

ហាន៖ ចុះឡានអាម៉េសេៗកង់ដបមានឡានអីមានពួកអាហ្នឹង មានពួកឡង់រីវែដឹកចូល ។

វណ្ណៈ៖ ចឹងពូនៅហ្នឹងបានតែ៦ខែទេ ពូចេញមកទៀត?

ហាន៖ បាទ ។

វណ្ណៈ៖ ចឹងពូនៅហ្នឹងដឹងថាគេដឹកចេញដឹកចូលយកទោសសម្លាប់តែពូមិនដែលឃើញគេវៃផ្ទាល់ទេ គ្រាន់ដឹងថាអ្នកទោសមានប្រជាជនអត់បាយដឹង?

ហាន៖ ដឹងគ្រាន់តែគេយកទៅធ្វើយ៉ាងម៉េចអីយ៉ាងម៉េច គេយកចេញពីកន្លែងយាមទៅហើយទៅពីហ្នឹងទៀតមិនដឹងជាយ៉ាងម៉េចខ្ញុំអត់ដឹងទេ ។

វណ្ណៈ៖ ចឹងគ្រាន់តែពូបានដឹងថា មានគេសម្លាប់មនុស្សអីចឹងមែនពូ?

ហាន៖ បាទ!មានមែន ។

វណ្ណៈ៖ ចឹងអ្នកទោសហ្នឹងពូសង្កេតមើលអ្នកទោសជាយោធាខ្មែរក្រហមដែលឬក៏ជាប្រជាជនសុទ្ធសាធ?

ហាន៖ ភាគច្រើនយោធាមានអីក៏មាន ភាគច្រើនដូចជាខ្ញុំនិយាយជាមួយបងកាលពីខាងដើមចឹងអ្នកខ្លះខុសចឹងគេចាប់ពីក្រុមមួយទៅក្រុមមួយចឹង តែដឹងយ៉ាងម៉េចខ្ញុំខុសដែលបានជាគេមិនចាប់ជំនាន់ហ្នឹងកំរករស់ណាស់ ឲ្យតែអ្នកធ្វើខុស ។

វណ្ណៈ៖ ប្រជាជនថ្មីអីចឹង?

ហាន៖ ដូនកាលអ្នកថ្មី កាលហ្នឹងអ្នកថ្មីក៏ខុសច្របូកច្របល់ ។

វណ្ណៈ៖ ចឹងភាគច្រើនយោធាអីគេចាប់?

ហាន៖ ភាគច្រើនអ្នកនៅក្នុងកងហ្នឹង ។

វណ្ណៈ៖ ចឹងកាលដែលគេចាប់រស់ ញ៉ឹមអីពូមានបានដឹងទេ កាលហ្នឹង?

ហាន៖ កាលហ្នឹងខ្ញុំដឹង ខ្ញុំដឹងថាគេដេញចាប់បាត់ដបងហ្នឹងដែរ កាលហ្នឹងខ្ញុំនៅអីណាទេ ទៅប៉ៃលិនវិញមិនដឹងអីមិនដឹង កាលគេចាប់នៅនេះខ្ញុំទៅនោះផុត ។

វណ្ណៈ៖ ចឹងកាលហ្នឹងតា ម៉ុកចុះទៅដែរ?

ហាន៖ បាទ ។

វណ្ណៈ៖ កាលហ្នឹងតា ម៉ុកចុះទៅចុះអីដែលហ្នឹង?

ហាន៖ បាទ ។

វណ្ណៈ	ហើយកូនគាត់ឈ្មោះ ឆ្នាំងឈ្មោះអី ។

ហានៈ	បាទៗ !ហ្នឹងហើយ នៅទាល់រាល់ថ្ងៃហ្នឹង ។

វណ្ណៈ	ឈ្មោះឆ្នាំងមាននៅណា គេចាប់ដែលហ្នឹង?

ហានៈ	អត់នៅទេ គេចាប់ដែលហ្នឹង ។

វណ្ណៈ	គេចាប់ទាំងអស់ទាំងឪពុកទាំងកូនអី តា រស់ ញ៉ឹមហ្នឹងគាត់ត្រូវជាជនួនជាមួយសោភីមពូមានបានដឹងចឹងដែរ?

ហានៈ	ដឹង ។

វណ្ណៈ	ចឹងពូដឹងដែរ?

ហានៈ	បាទ ។

វណ្ណៈ	ចឹងកូនសោភីមឈ្មោះអីដែលបានយកជាមួយកូនសោភីមពូមានស្គាល់ទេ?

ហានៈ	ខ្ញុំដូចជាភ្លេចបានហើយខ្ញុំ ។

វណ្ណៈ	ចឹងកាលហ្នឹងពូនៅតបន់ប៉ុន្មានកាលនៅបាត់ដំបងហ្នឹង?

ហានៈ	កាលហ្នឹងខ្ញុំនៅតំបន់៣បាត់ដំបងយើងហ្នឹង ។

វណ្ណៈ	នៅតំបន់៣តាមខ្ញុំដឹងមានមេឃុំមួយឈ្មោះរស់ លី តាហ្នឹងសព្វថ្ងៃគាត់នៅធ្វើបុណ្យអីដែរ តា ញ៉ឹកលី តា ញ៉ឹកលីហ្នឹងពូមានស្គាល់ទេ គាត់ជាមេឃុំនៅហ្នឹងប្រជាជននៅហ្នឹងថាតា ញ៉ឹក លីហ្នឹងស្លូតទេ គាត់ជួយឧបត្ថមប្រជាជនកាលជំនាន់ហ្នឹង?

ហានៈ	ឥឡូវគាត់ជាមេឃុំនៅហ្នឹងដែរ?

វណ្ណៈ	ឥឡូវគាត់អត់មានជាមេឃុំទេ គាត់ជាអាចារ្យហើយនៅវត្តនៅអីហើយមានរត់ទៅអូស្ត្រាលីបានផ្ញើលុយឲ្យគាត់ចាយ ។

ហានៈ	បាទ ។

វណ្ណៈ	ហើយខ្ញុំបានសួរប្រជាជនហើយ កាលហ្នឹងនៅតំបន់៤តំបន់៥ វេទនាអីហ្នឹងបើបានរត់ចូលតំបន់បីហ្នឹងគាត់ជួយការពារបាន មិនសូវមានគ្រោះថ្នាក់ទេ តែពូនៅតំបន់បីមិនសូវមានបញ្ហាទេ តែពូនៅជាយោធា?

ហានៈ	ខ្ញុំនៅខាងយោធា អត់ខាងប្រជាពលរដ្ឋទេ ។

វណ្ណៈ	តែពូកាលហ្នឹងបានដឹងថា គេចាប់មនុស្សយកទៅដាក់វត្តប្រកិតហ្នឹង?

ហានៈ	មានមែន ។

វណ្ណៈ	ចឹងពូមកកងវរៈ២១ហ្នឹង មកការពារព្រំដែនវិញឬមួយមកនៅកន្លែងណា?

ហនៈ ខ្ញុំនៅហ្នឹងវិញដដែលហ្នឹង ។

វណ្ណៈ នៅណា?

ហនៈ នៅបាត់ដំបងនិងដដែលហ្នឹង ។

វណ្ណៈ នៅបាត់ដំបងហ្នឹងនៅធ្វើអី?

ហនៈ ពេលហ្នឹងខ្ញុំឈប់តស៊ូហើយខ្ញុំមកជួបម៉ែខ្ញុំហើយ ខ្ញុំមកជួបម៉ែខ្ញុំហើយកាលូតស៊ូមិនបាន ឃើញម៉ែខ្ញុំទេ ។

វណ្ណៈ ចឹងពូថាមកនៅវរៈ២១នោះ?

ហនៈ នៅវរៈ២១ហ្នឹងខ្ញុំនៅហ្នឹងមិនដុំទេ មិនទាន់ដឹងទេ ។

វណ្ណៈ ចឹងឆ្នាំណាបានពូមកជុំម៉ែឪវិញ?

ហនៈ មកជុំម៉ែខ្ញុំឆ្នាំ៨៣បានខ្ញុំរកម៉ែខ្ញុំឃើញ ។

វណ្ណៈ ចឹងក្រោយមកទៀតទេ ចឹងពូមកនៅវរៈ២១ហ្នឹងនៅបាត់ដំបងដែរ?

ហនៈ បាទ ។

វណ្ណៈ ចឹងពូការពារព្រំដែនក៏បានរយៈពេលខ្លីដែរ?

ហនៈ បាទ! ខ្លីដែលហ្នឹងទៅមកៗហ្នឹង ។

វណ្ណៈ ចឹងការពារព្រំដែនហើយគេបញ្ជូនពូទៅបាត់ដំបងវិញ?

ហនៈ បាទ ។

វណ្ណៈ យាមអ្នកទោសអីចឹង?

ហនៈ បាទ ។

វណ្ណៈ ចឹងពេលពូមានបញ្ហាបានពូទៅនៅវរៈ២១?

ហនៈ បាទ ។

វណ្ណៈ វរៈសេនាតូច២១វិញ?

ហនៈ បាទ ។

វណ្ណៈ ចឹងនៅកងវរៈ២១គេធ្វើអីដែរ?

ហនៈ កងវរៈសេនាតូច២១ហ្នឹង គេដើរយាមអីខាងសន្តិសុខគេហ្នឹង ។

វណ្ណៈ យាមសន្តិសុខឬយាមក្រុង?

ហនៈ យាមក្រុង ។

វណ្ណៈ ចឹងយាមក្រុងរហូតដល់៧៩?

ហានៈ ហ្នឹងហើយ ។

វណ្ណៈ ចឹងនៅពេលវៀតណាមចូលពួរត់ទៅខាងណា?

ហានៈ វៀតណាមចូលខ្ញុំនៅហ្នឹង ។

វណ្ណៈ នៅណា?

ហានៈ ខ្ញុំនៅបាត់ដំបងហ្នឹង ។

វណ្ណៈ ចឹងអត់រត់ទេ?

ហានៈ អត់រត់ទេ ។

វណ្ណៈ នៅផ្ទះរហូត?

ហានៈ គ្រាន់តែទម្លាក់កាំភ្លើងនៅហ្នឹងបណ្តោយ មិនមានចូលព្រៃចូលអីទៀតទេ ។

វណ្ណៈ ចឹង៧៩ហ្នឹងពូនៅបាត់ដំបងជួបជុំម៉ែឪបងប្អូនហើយចឹង?

ហានៈ បាទ ។

វណ្ណៈ ចឹងក្រោយមកទៀតពូបានរៀបការជាមីងឆ្នាំណាទៅ ៧៩ហើយពូមិនទាន់ទេ ពូនៅកំលោះនៅឡើយ?

ហានៈ បាទ ។

វណ្ណៈ ពូចូលធ្វើទាហានទៀតឬអត់ទេ ធ្វើជាប្រជាជនធម្មតា?

ហានៈ ចូលទៀត ពេលហ្នឹង៧៩ហើយគេរៀបរយហើយគ្រប់គ្រាន់ហើយអស់ហើយគេចាប់ផ្តើមចោទខ្ញុំហើយ មានប្រធានភូមិមានអីហើយហ្នឹង ។

វណ្ណៈ ចឹងប្រធានភូមិចោទពូ?

ហានៈ បាទ ។

វណ្ណៈ ចោទ ពូថាម៉េច?

ហានៈ គេចាប់ផ្តើមចោទ ខ្ញុំថាអ្នកតស៊ូអ្នកអីណានៅខ្មែរក្រហមណាណីគេមិនឲ្យនៅក្នុងស្រុកក្នុងភូមិខ្ញុំភ័យខ្ញុំរត់មួយសាទៀត បែកម៉ែខ្ញុំមួយសារទៀត ។

វណ្ណៈ ចឹងឆ្នាំណាដែលពូលែងបាននៅភូមិ?

ហានៈ លែងនៅភូមិ៨៣ ។

វណ្ណៈ ចឹងឆ្នាំ១៩៨៣?

ហានៈ បាទ ។

វណ្ណៈ ចូលព្រៃទៀត?

ហនៈ ចូលព្រៃទៀត ។

វណ្ណៈ ចូលព្រៃខាងណា?

ហនៈ ខាងយើងប៉ៃលិនវិញដដែល ។

វណ្ណៈ នៅខាងប៉ៃលិន?

ហនៈ បាទ ។

វណ្ណៈ វៃជាមួយទាហាន?

ហនៈ វៃជាមួយទាហានលោកហ៊ុន សែនរហូតដល់ចូលជាមួយរដ្ឋាភិបាល ។

វណ្ណៈ ចឹងរហូតដល់មានសមាហរណ៍កម្ម?

ហនៈ បាទ ។

វណ្ណៈ ចឹងកាលហ្នឹងពូនៅខាងប៉ៃលិនប្រធានកងពលពីណាគេ?

ហនៈ អ៊ី ឈាន ។

វណ្ណៈ ចឹងអ៊ី ឈាន?

ហនៈ បាទ ។

វណ្ណៈ អនុកងពលពីណា?

ហនៈ បង វឿន ។

វណ្ណៈ គាត់ឈ្មោះអីវឿន?

ហនៈ មិនដឹងជាស្អីវឿនទេ ខ្ញុំភ្លេចបាត់ហើយ ។

វណ្ណៈ បើនៅខាងម៉ាឡៃមានតា ហុង តា សេងពូមានស្គាល់ដែលខាងហ្នឹង?

ហនៈ គ្រាន់តែស្គាល់ត្រឹតែឈ្មោះ ។

វណ្ណៈ ចឹងកាលពូនៅប៉ៃលិនហ្នឹងពូវៃជាមួយទាហានរដ្ឋកម្ពុជាជាមួយទាហានវៀតណាមអីហ្នឹង កាលហ្នឹងមានទាហានវៀតណាមអីស្លាប់ច្រើនទេ?

ហនៈ ឃើញមានពេលហ្នឹងឃើញមានដួលខ្លះៗ ហើយហ្នឹង គេបាញ់យើងយើងបាញ់គេហើយ ។

វណ្ណៈ ចឹងកាលហ្នឹងខាងខ្មែរក្រហមស្លាប់តិចជាងទេ?

ហនៈ ខាងខ្មែរក្រហមស្លាប់តិចជាង ព្រោះខ្មែរក្រហមកំលាំងគេវាតិចពីរបីនាក់ចឹងទៅបាញ់ជាមួយទាហានរដ្ឋកម្ពុជាទាហានវៀតណាម១០ទៅ២០នាក់ប្រមួយកងទៅ ។

វណ្ណៈ ស្លាប់តិចប៉ុន្តែមានឈឺដោយសារគ្រុនចាញ់មានច្រើនដែរ?

ហនៈ មាន ។

វណ្ណៈ តែមានថ្នាក់ព្យាបាលគ្រប់គ្រាន់ដែរ?

ហានៈ មានថ្នាំគ្រប់គ្រាន់បរបូរមានមន្ទីរពេទ្យគ្រប់គ្រាន់និងសង្គ្រោះនិងចាប់ផ្តើមមានអ្នកជំងឺអីបញ្ជូនទៅខាងថៃវិញហើយ ។

វណ្ណៈ ចឹងកាលហ្នឹងអាវុធដែលខ្មែរក្រហមទទួលបានមកពីចិនដដែលឬយ៉ាងម៉េច?

ហានៈ មកពីចិនដដែល ។

វណ្ណៈ ចឹងនៅពេលវៃចាញ់យួន យួនវៃបុកធ្លាយចូលដីថៃអី ថៃអត់មានរករឿងយើងទេ?

ហានៈ អត់ទេ អត់មានរករឿងអីទេ វាបើកឲ្យចូលទៅស្នាក់នៅបណ្តោះអាសន្នចឹងទៅ ដល់គេដកមកវិញគេឲ្យយើងមកវិញមកតាមព្រំដែន ដែនដីយើងវិញមក ។

វណ្ណៈ ចឹងកាលហ្នឹងពូមានដឹងពីមូលទេ ដែលថៃបានអនុគ្រោះដល់ទាហានខ្មែរក្រហម ពូមានដឹងគោលការណ៍ថាថៃវាមានផលប្រយោជន៍អី មានចំណេញអីពីខាងខ្មែរក្រហមបានជាផ្តល់ទីតាំងជំរកឲ្យខាងខ្មែរក្រហម?

ហានៈ ខ្ញុំជឿថាមានផលប្រយោជន៍ តែមិនដឹងជាផលប្រយោជន៍ខាងលើគាត់និយាយខាងផ្នែកនយោបាយអីយ៉ាងម៉េចៗ អ្នកទាំងពីរហ្នឹងខ្ញុំមិនបានដឹងទេ ។

វណ្ណៈ បាទ!ចឹងថៃមានផលប្រយោជន៍?

ហានៈ បាទ ។

វណ្ណៈ ចឹងកាលហ្នឹងបានឃើញព្រៃឈើមានច្រើនរបៀបយ៉ាងម៉េចពូ បើប្រៀបធៀបមកឥឡូវឥឡូវមានបាត់បង់ច្រើនប៉ុណ្ណាទៅយ៉ាងម៉េចដែរ?

ហានៈ និយាយទៅព្រៃឈើវាអស់ កាលខ្មែរក្រហមនៅសត្វសម្បូរជាងវិញបាញ់ផ្លូងដាំងក្បែរផ្ទះនៅមានសត្វព្រៃឈើឡើងទៅនៅបរបូរវានៅមួយរយភាគរយទាំងអស់ ដល់ក្រោយមកអស់ខ្មែរក្រហមទៅមានអរក្សសត្វហ្នឹងមកសត្វទៅជាអត់ទៅជាយ៉ាងម៉េចវិញម៉េចមិនដឹងទៅជាបាត់សត្វអស់ទៅ កាលជំនាន់នៅសង្គ្រាមភីសភូសដើរទៅណាក៏ជួបសត្វ ឥឡូវដើរបីថ្ងៃអត់មានជួបសត្វ ។

វណ្ណៈ ចឹងពូដឹងថាដោយសារអីបានជាអត់មានសត្វ?

ហានៈ ខ្ញុំមិនដឹងជាដោយសារអី ខ្ញុំគិតឃើញកាលពីខ្ញុំនៅសង្គ្រាមគ្រាន់ដើរជួនកាលបាញ់ទាំងថ្ងៃជួបសត្វទាំងហ្វូងៗដែលបាញ់ផ្លូងភាំងរាល់ថ្ងៃសោះ ដល់ក្រោយមកវាស្ងាត ដល់ក្រោយមកមានអរក្សមានអីទប់ស្កាត់អីណា មានដីអរក្សអីណាសត្វមិនដឹងជាបាត់ទៅណាខ្ញុំឆ្ងល់ត្រង់ហ្នឹងដែរ ។

វណ្ណៈ	តែនៅខាងសំឡូង កំរៀង ប៉ៃលិនដោយសារអត់មានព្រៃពូ?

ហានៈ	បាទ ។

វណ្ណៈ	កាលហ្នឹងគេថាព្រៃច្រើនណាស់ កាលហ្នឹងគេថាចូលទៅមើលព្រៃមិនឃើញណានោះ?

ហានៈ	បាទ ។

វណ្ណៈ	ខ្ញុំមិនដែលបានដឹងទេ តែខ្ញុំទៅសម្ភាសន៍ ។

ហានៈ	និយាយពីរឿងព្រៃជំនាន់ខ្មែរក្រហមនៅព្រៃមែន មានឈើតូចឈើធំមានទាំងអស់មែន ។

វណ្ណៈ	ចឹងណាមានព្រៃច្រើនសត្វវាមានហើយ?

ហានៈ	បាទ ។

វណ្ណៈ	ចឹងឥឡូវវាអាចរត់ទៅស្រុកគេទៅ ដោយសារយើងកាប់និងរណាអាលាន់ពូ្រងើងៗពេញព្រៃទៅ?

ហានៈ	បាទ ។

វណ្ណៈ	វាភ័យហើយវាអត់មានជំរកចឹងបានជាសត្វរត់ទៅស្រុកគេ ទៅថៃទៅអីហ្នឹង?

ហានៈ	កាលជំនាន់ហ្នឹងបងខ្ញុំទៅចំការចឹងក៏ត្រូវដែលវាចឹងមែន កាលហ្នឹងវានៅព្រៃយើងច្រើនហើយមនុស្សក៏វាអាចតិចដែលបាញ់ផ្លូងផាំងទៅតែសត្វនៅសម្បូបាន ។

វណ្ណៈ	ចឹងកាលហ្នឹងមនុស្សក៏តិចដែរ?

ហានៈ	បាទ ។

វណ្ណៈ	ចឹងដូចជាជើងពូដាច់នៅឆ្នាំណា?

ហានៈ	ឆ្នាំ៩៧ ។

វណ្ណៈ	៩៧ហ្នឹងដោយជាន់មីនពូ?

ហានៈ	ជាន់មីន ។

វណ្ណៈ	ជាន់មីនហ្នឹងពូជាន់មីនដោយសារពូកាប់ឆ្ការព្រៃយកដីឬពូជាន់មីនដោយសារសង្គ្រាម?

ហានៈ	សង្គ្រាមខ្ញុំបញ្ឈាទ័ព ខ្ញុំបញ្ឈាទ័ពខ្ញុំខឹងទ័ពខ្ញុំទៅមើលភូមិសាស្រ្តខ្លួនឯងជាន់បណ្តោយ រកកន្លែងលាក់ទ័ពកាលហ្នឹង ខ្ញុំប្រធានវរៈហើយ ។

វណ្ណៈ	ចឹង៩៧ពូជាប្រធានវៈ?

ហានៈ	បាទ ។

វណ្ណៈ	ប្រធានវរៈសេនាធំសេនាតូច?

ហានៈ	វរៈសេនាតូច ។

វណ្ណៈ ពេលពួជាច់ដើងចឹងគេព្យាបាលពួនៅហ្នឹងឬមួយយកទៅថៃ?

ហានៈ មើលទីតាំងខ្ញុំដាច់ជើងនៅយើងអូរសោមនេះ ខ្នងទឹកវែងខាងផ្ទះមួយហ្នឹង ចឹងគេបញ្ជូនខ្ញុំទៅខាងកោះកុងដំបូង ។

វណ្ណៈ បាទ ។

ហានៈ បានទៅកោះកុងចឹងទៅបានបង មាស សុភាគាត់មកយក គាត់យកយន្តហោះមកយកនៅយើងកោះកុងនេះយកទៅដាក់ពេទ្យ១-៧៩ ។

វណ្ណៈ ខាងរដ្ឋកម្ពុជាមកយកវិញ?

ហានៈ បាទ ។

វណ្ណៈ មាស សុភា?

ហានៈ បាទ ។

វណ្ណៈ គាត់ផ្កាយមាស៤រាល់ថ្ងៃហ្នឹង?

ហានៈ បាទ ។

វណ្ណៈ ចឹងមានន័យថាចរចារគ្នាត្រូវហើយ?

ហានៈ ចរចារគ្នាត្រូវហើយខ្ញុំដាច់ជើង ខ្ញុំមុនដាច់ជើងគេចរចារគ្នាត្រូវតាំងពីប៉ៃលិនអីណាមកអស់ហើយ ។

វណ្ណៈ ចឹង៩៧ហ្នឹងសមាករណ៍កម្មហើយ?

ហានៈ បាទ!សមាហរណ៍កម្មហើយគេត្រូវគ្នាហើយហ្នឹង ខ្ញុំមកជាទាហានខាងក្នុងនេះហើយហ្នឹង ។

វណ្ណៈ ចឹងកាលហ្នឹងពួឈប់ជាទាហានខ្មែរក្រហម មកចូលជាមួយទាហានរដ្ឋកម្ពុជាទៀត?

ហានៈ កាលហ្នឹងខ្ញុំជាទាហានខ្មែរក្រហម ពេលហ្នឹងទាហានខ្មែរក្រហមមិនធ្វើសមាហរណ៍កម្ម កាលហ្នឹងគេទៅណា៨ខែណាទៅម៉ាព្រុសហ្នឹងនោះ មិនបាញ់គ្នាមួយសារខ្មែរក្រហមនិងខ្មែរក្រហមហ្នឹង ។

វណ្ណៈ បាទ ។

ហានៈ ចឹងខ្ញុំដាច់ជើងហ្នឹង ខ្ញុំតស៊ូមកទាហានយើងរដ្ឋកម្ពុជានេះហើយ ខ្ញុំមកនេះហើយខ្ញុំបញ្ឈទ័ពហើយហ្នឹង ។

វណ្ណៈ បញ្ឈទ័ពនៅជាមួយខាងណាទៀត?

ហានៈ ខាងខ្មែរក្រហមយើងខាងហ្នឹងនៅអាគ្នាឯងហ្នឹង ។

វណ្ណៈ ចឹង?

ហានៈ កំលាំងខ្ញុំខាងនេះខ្ញុំថ្មីមែនតែខ្ញុំមានតួនាទីជាប្រធានវរៈហើយ ខ្ញុំគ្រប់គ្រងវរៈហើយ ។

វណ្ណៈ ចឹងពូទៅព្យាបាលនៅពេទ្យណា?

ហានៈ ពេទ្យ១-៧៩ ។

វណ្ណៈ ចឹងកាលពូត្រូវក្លាមចឹងត្រូវដឹងចឹង ពូឈឺខ្លាំងឬពូស្ពឹកអស់ហើយ?

ហានៈ ត្រូវម៉ាដឹងដំបូងខ្ញុំមិនដឹងថាខ្ញុំដាន់មីនដងហ្នឹង ខ្ញុំថាគេបាញ់ខ្ញុំហ្នឹង ស្រាប់តែខាងអង្គរក្សខ្ញុំស្រែកមកថាបងដាន់មីនហើយបង ដាន់មីនហើយគេធ្វើរបួសជាក់ស្តែងនៅកន្លែងប្រយុទ្ធ កន្លែងសមរភូមិហ្នឹង ។

វណ្ណៈ ចឹងពូអត់មានសន្ទប់ទេ?

ហានៈ ខ្ញុំអត់មានសន្ទប់ទេ ដឹងថាគេធ្វើស៊ីទៀតដឹងៗស៊ីៗទាំងអស់ បានស្រែកដេរអង្គរក្សខ្ញុំទៀតណាស់ ចុះឯងចាំស៊ីទៀតគេបាញ់ផាប់ឥឡូវឯងយកអញទៅឲ្យលឿន ។

វណ្ណៈ ចឹងអារម្មណ៍ពេលហ្នឹងអត់មានរវើរវាយអីទេ?

ហានៈ អារម្មណ៍អត់មានស្អុតអីទេ ផ្តែផ្តាំឲ្យមេក្រុមៗមើលកំលាំងយើងទៅ អញដាច់ជើងហើយ អញមិនដឹងជារស់មិនជាផាប់ខ្ញុំតស៊ូទំរុញកំលាំងយើងបន្ថែមទៅ មានផ្តែផ្តាំចឹងទៀត ។

វណ្ណៈ ចឹងកាលហ្នឹងចូលមកខាងរដ្ឋកម្ពុជាវៃខ្មែរក្រហមវិញទៀត?

ហានៈ បាទ!ហ្នឹងហើយ ។

វណ្ណៈ ចឹងពូនៅដូចថាខ្មែរក្រហមចូលសមាហរណ៍កម្មមែនទេ?

ហានៈ បាទ ។

វណ្ណៈ ចឹងសមាហរណ៍កម្មហើយពូចូលជាមួយរដ្ឋកម្ពុជាវិញ?

ហានៈ បាទ ។

វណ្ណៈ ភ្លាមៗហ្នឹង?

ហានៈ ភ្លាមៗហ្នឹង កាលហ្នឹងមិនមែនទៅតែខ្ញុំម្នាក់ទេ សមាហរណ៍កម្មភ្លាមៗហ្នឹងទៅទាំងកងពលមេខ្ញុំរាល់ថ្ងៃគឹម ពៅនៅគ្រួសយើងចេញពីខាងលិចពោធិ៍សាត់បន្តិចមកហ្នឹង ។

វណ្ណៈ ចឹងវៃខ្មែរក្រហមគ្នាឯងវិញ?

ហានៈ បាទ ។

វណ្ណៈ ចឹងនៅពេលវៃមួយប្រាវចឹងទៅលែងមានសង្គ្រាមហើយ?

ហានៈ លែងមានសង្គ្រាមហើយយើងត្រូវគ្នាវិញអស់ហើយ ។

វណ្ណៈ ចឹងត្រូវគ្នាវិញអស់ហ្នឹងប្រហែលជា៩០ប៉ុន្មាន៩៧ឬ៩៨?

ហានៈ ៩៨ ។

វណ្ណៈ ចឹង៩៨ត្រូវគ្នាហើយ?

ហានៈ បាទ ។

វណ្ណៈ ចឹងត្រូវគ្នាមានបានបោះឆ្នោតទេ នៅឆ្នាំ៩៨?

ហានៈ បានបោះតើខ្ញុំដាច់ជើងហើយខ្ញុំបោះឆ្នោត ។

វណ្ណៈ ចឹងបោះឆ្នោតហើយយើងបានរៀបចំភូមិសន្តាត់ចឹងទៅ?

ហានៈ យើងបានរៀបចំភូមិសន្តាត់ហើយ ។

វណ្ណៈ ចឹងកាល៩៨ហ្នឹងសម័យខ្មែរក្រហមអីពូនៅហ្នឹងតែម្តងឬនៅណាកាលហ្នឹងកាលហ្នឹង កាលពីឆ្នាំមើល៨៣ពូចូលទៅធ្វើទ័ព កាលហ្នឹងមានទីតាំងនៅហ្នឹងតែម្តង?

ហានៈ នៅហ្នឹងខ្ញុំនៅហ្នឹង ។

វណ្ណៈ ហើយពូរៀបការនៅណាដែរ?

ហានៈ ខ្ញុំការនៅខាងយើងសំឡូត ។

វណ្ណៈ ការនៅសំឡូតឆ្នាំណាការនៅសំឡូត?

ហានៈ កាលហ្នឹងការឆ្នាំណា៨៨អីមិនដឹង ។

វណ្ណៈ ការកាលហ្នឹងចាប់ដៃគ្នាឬមួយមានភ្លេងការហើយ?

ហានៈ មិនទាន់មានទេ កាលហ្នឹងការក្នុងខ្មែរក្រហមទេ ចាប់ដៃគ្នាប្តេជ្ញាមានមេអង្គការមានអីហ្នឹង ។

វណ្ណៈ ចឹងកាលហ្នឹងមានអង្គការចាប់ដៃគ្នាមិនទាន់មានភ្លេងការ?

ហានៈ បាទ ។

វណ្ណៈ ចឹងពូនៅសំឡូត?

ហានៈ នៅសំឡូត ។

វណ្ណៈ ចឹងឆ្នាំណាបានពូមកដល់ភូមិនេះ មកនៅភូមិស៊ីងថ្មីនេះ?

ហានៈ ខ្ញុំមកនៅភូមិស៊ីងថ្មីហ្នឹង មិនដឹងជាឆ្នាំប៉ុន្មានហើយទេ "អ្នកជិតខាងនិយាយថា៩៦" ។

វណ្ណៈ ៩៦កាលហ្នឹងមិនទាន់សមាហរណ៍កម្មដងចឹង?

ហានៈ នៅមិនទាន់មានសមាហរណ៍កម្មទេ ។

វណ្ណៈ កាលពូមកដល់ហ្នឹងដំបូងពូមានឃើញប្រជាជនច្រើនឬស្ងាត់ជ្រងំ?

ហានៈ អត់មានទេ មានសុទ្ធតែព្រៃនៅតែកងពលខ្ញុំមួយទេ ដែលមកមានភូមិមានអីនៅហ្នឹងមុន ។

វណ្ណៈ ចឹងមានបានធ្វើផ្ទះធំៗចឹងនៅ?

ហនៈ អត់ទេ អត់មានផ្ទះទេ អត់មានផ្ទះសំបែងទេ ។

វណ្ណៈ ចឹងអត់មានផ្ទះទេ?

ហនៈ មានផ្ទះតែពួកខ្ញុំមកនៅ តែមកដល់ហ្នឹងអត់មានឃើញផ្ទះឃើញអីទេ ។

វណ្ណៈ ចឹងម្ហូបអាហារបាយទឹកយើងធ្វើទំនាក់ទំនងយ៉ាងម៉េចទៅ យើងទំនាក់ទំនងជាមួយថៃយ៉ាងម៉េចទៅ?

ហនៈ ខ្ញុំមិនដឹងថាខាងលើដោះស្រាយយ៉ាងម៉េចអីយ៉ាងម៉េច ពេលយើងមកហ្នឹងមកមានសំភារមានម្ហូបមានបាយមានម្ហូបអាហារមកទាំងគ្រួសារមកទាំងអស់គ្នាបណ្តោយមានអង្ករមានអីមកជាមួយហ្នឹង ។

វណ្ណៈ ចឹងដោយសារថាពូធ្លាប់ឆ្លងកាត់ប្រវត្តិដល់ដូចត់ហើយមានរឿងរ៉ាវដូចថាល្អៗជាច្រើននិងមានបទពិសោធន៍កន្លងមកចឹង ហើយមកដល់ពេលហ្នឹងបើសិនជាពូត្រឡប់ទៅក្រោយវិញថា បើសិនជាពូគិតថា ឥឡូវនេះជំនាន់ឥឡូវនេះរកខ្លួនឯងហូបខ្លួនឯងហើយបើប្រៀបធៀបក្រោយ៧៩ ក្រោយ៧៩សម័យតស៊ូនៅប៉ៃលិនជាមួយអ៊ុំ ឈានចឹង ពូគិតថាពេលហ្នឹងកាលមិនទាន់ត្រូវគ្នាស្រួលជាងឬក៏ឥឡូវស្រួលជាង បើតាមយោបល់របស់ពូមតិពូផ្ទាល់?

ហនៈ ខ្ញុំថា ដូចជាមិនជាងគ្នាទេ បើនិយាយទៅខ្ញុំថា កាលពីមិនទាន់ត្រូវគ្នាចង់ស្រួលជាងយើងឥឡូវនេះផង ។

វណ្ណៈ ស្រួលយ៉ាងម៉េចខ្លះ?

ហនៈ ស្រួលជាងយ៉ាងម៉េច វាអត់បារម្ភណ៍វាអត់ពិបាកអីគេឲ្យទៅណាទៅហ្នឹងទៅអត់មានពិបាករឿងសម្លៀកបំពាក់ខ្វាចអត់ខ្វាចអីទេ អត់មានខ្វាចប្រពន្ធកូនអត់បាយអត់ទឹកដូចយើងរាល់ថ្ងៃនេះអត់ទេ គេឲ្យយើងទាំងអស់ កូនឈឺគេមើលឲ្យយើងទៀត គេបញ្ជូនៗបញ្ជូនខ្លួនគេទៀតអត់មានពិបាកទេ ។

វណ្ណៈ ចឹងទោះបីជាអត់មានភ្លើងអីក៏ដោយពូគិតថារស់នៅបែបហ្នឹងស្រួលជាង អត់មានផ្លូវក៏ដោយ?

ហនៈ បាទ ។

វណ្ណៈ កាលហ្នឹងស្រួលជាង?

ហនៈ ស្រួលជាង ។

វណ្ណៈ ចឹងឥឡូវពិបាកជាងវិញ?

ហនៈ ឥឡូវមិនជាពិបាកអី គ្រាន់តែយើងពិបាកគិតវាច្រើនជាងពីមុន ពិបាកគិតក្នុងក្រុមគ្រួសារ ទី១វាអត់ អនាគតទៅថ្ងៃមុខមិនដឹងជាយ៉ាងម៉េចអី ត្រូវធ្វើអីរកអីហ្នឹងវាពិបាកត្រង់ហ្នឹងទេ បើពីមុនមកយើងអត់មានគិតខ្វាចអត់អី អត់មានទេ ។

វណ្ណៈ ចឹងកាលហ្នឹងកូនចៅពូមានបានរៀនទេឬមួយអត់ទេ កាលសម័យតស៊ូ?

ហនៈ កាលសម័យតស៊ូអត់ទាន់មានកូនរៀនដងហ្នឹង ។

វណ្ណៈ ចឹងឥឡូវពូបានកូនរៀន?

ហនៈ ឥឡូវបានកូនរៀន ។

វណ្ណៈ ចឹងខ្ញុំដូចជាអស់អីចង់សួរពូហើយ តើពូមានអីចឹងនិយាយបន្ថែមទៀតឬមួយពូមានឆ្ងល់អីទេ ដែលពូ ពូអាចសួរបាន?

ហនៈ ចេះខ្ញុំឆ្ងល់សួរនៅខាងអស់លោកខាងនេះវិញ ខ្ញុំចង់សួរថា ការសម្លាស ការកំណត់ហេតុពី ខ្ញុំ ខ្ញុំនិយាយខ្ញុំរ៉ាវពីខាងដើមមកណាស់ ។

វណ្ណៈ បាទ ។

ហនៈ ថាអស់លោកចងក្រងទុកជាកំណត់ហេតុបញ្ជូនយកទៅឲ្យខាងណាឬមួយកំណត់ហេតុទុកដើម្បី យ៉ាងម៉េចមួយ សូមឲ្យអស់លោកជួយពន្យល់ត្រង់ហ្នឹងបន្តិចមើល ។

វណ្ណៈ បាទ!ខ្ញុំជំរាបជូនពូបានថា ខ្ញុំមកពីអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា អង្គការខ្ញុំមិនបានពាក់ព័ន្ធជាមួយរដ្ឋាភិបាល មិននៅក្រោមចំណុះពីណាមួយ យើងបានទទួលជំនួយពីខាងបរទេស មកពីប្រទេសផ្សេងៗឬមួយអាមេរិច ប្រទេសហូឡង់ឬមួយប្រទេសផ្សេងៗទៀតគេជួយឲ្យ យើងក្នុងន័យស្រាវជ្រាវ ដើម្បីជួយរកយុត្តិធម៌ចង់ដឹងថា អ្នកណាខុសអ្នកណាត្រូវហើយ ចង់ចងក្រងទុកជាប្រវត្តិសាស្រ្ត ។ មិនមែនយកបទសម្ភាសពីទៅស្អែកឡើងចាក់នៅតាមទូរទស្សន៍អីទេ គឺអត់មានទេ ពូចាំមើលចុះមិនមានទេ គ្រាន់តែចង់ក្រងជាប្រវត្តិសាស្រ្តដើម្បីឲ្យ ក្មេងជំនាន់ក្រោយបានរៀនសូត្រ ។ ឲ្យបានដឹងថាពីមុនខ្មែរយើងវ៉ៃគ្នាឯងខ្មែរយើងត្រូវគេ សម្លាប់ ខ្មែរយើងត្រូវអត់បាយអត់ទឹក ហើយរហូតប្រទេសយើងជួបតែសង្រ្គាមក្រមក ដល់សព្វថ្ងៃនេះ ។ គេមានអស់ហើយ នៅតែប្រទេសយើងគេចាត់ទុកជាប្រទេសអ្នកក្រនៅ ឡើយទេ មិនទាន់ក្លាយជាប្រទេសអ្នកមានទេ ។ ចឹងរឿងរ៉ាវទាំងអស់ហ្នឹងត្រូវបានយើងចង ក្រងទុកដើម្បីឲ្យក្មេងបានដឹងបានឮ អត់មានបញ្ជាយកទៅណាយកទៅណីទេ អត់មានទេ ។

ហនៈ បាទ ។

| | |
|---|---|
| វណ្ណៈ | អត់មានបញ្ហាអីទាំងអស់ គ្រាន់តែបទសម្ភាសពីហ្នឹងខ្ញុំសុំអនុញ្ញាតពីពូហ្នឹងយកទៅសរសេរជាសៀវភៅជាអីចឹងពូ ។ |
| ហានៈ | បាទ ។ |
| វណ្ណៈ | ចឹងពូមិនថាអីទេ? |
| ហានៈ | អត់មានថាអីទេ "ប្រពន្ធគាត់និយាយថា ទុកឲ្យក្មេងជំនាន់ក្រោយ" ។ |
| វណ្ណៈ | បាទ!ឲ្យវាបានដឹងបើយើងនិយាយមាត់ទទេ ក្មេងវាមិនជឿទេ ចឹងបើជាយើងនិយាយថាកាលជំនាន់ពុក កូនអត់មានបាយហូបបបរធ្វើការអត់សម្រាកវាអត់មានជឿទេ ក្មេងឥឡូវវាជឿទេ ព្រោះក្មេងឥឡូវវាកើតមកមានបាយទឹកហូបគ្រប់គ្រាន់ហើយដើរលេងសប្បាយចឹងណាស់ ។ |
| ហានៈ | តាមអស់លោកមកសម្ភាសមិញហ្នឹង តាមចិត្តខ្ញុំវិញខ្ញុំមិនចង់សម្ភាសទេ ឥឡូវបានភូមិនាំមកហើយ បើអត់ភូមិមកខ្ញុំអត់សម្ភាសមែនតើ ។ |
| វណ្ណៈ | ចឹង? |
| ហានៈ | បាទ!ខ្ញុំគ្រាន់តែឃើញមកហ្នឹង គាត់សម្ភាសហ្នឹងច្បាប់ក្នុងសៀវភៅហ្នឹងខ្ញុំបានរៀនខ្ញុំបានទទួលមួយច្បាប់ពីមុនមកហើយ ទើបប្រពន្ធកូនខ្ញុំរើសៀវភៅហ្នឹងចោលដាក់ទំលាក់ចោលត្រូវទឹកខ្ទិចអស់ទេ ។ |
| វណ្ណៈ | ហ្នឹង ។ |
| ហានៈ | ព្រោះខ្ញុំដឹងសាច់រឿងដឹងយ៉ាងម៉េចថា ច្បាប់សួរហ្នឹងខ្ញុំដឹងថាមកស្រាវជ្រាវអ្នកតស៊ូពីមុនៗមកព្រោះខ្ញុំធ្លាប់រៀនហើយ ឥឡូវមុនគេស្រាវជ្រាវតាំងពូមេៗចាស់ចឹងៗមករហូតគេចងក្រងចឹងទុកដូចគ្នា ។ |
| វណ្ណៈ | បាទ ។ |
| ហានៈ | ក្រោយមកពុះឡើងអ្នកដែលមេៗខ្មែរក្រហមរស់មិនយូរមិនដឹងជាយ៉ាងម៉េចអីយ៉ាងម៉េចទេមិនដឹងទេ គេឲ្យសុខមិនឲ្យមិនដឹងទេ ។ |
| វណ្ណៈ | ចឹងបើពូនិយាយដល់ចំណុចហ្នឹង យើងនិយាយចំណុចដល់តុលាការបន្តិចុះពូ យើងគ្រាន់ពិភាក្សាគ្នាលេង ។ |
| ហានៈ | បាទ ។ |
| វណ្ណៈ | ឧបមាថានៅប្រទេសមួយ ដូចជាប្រទេសយើងក៏ជាប្រទេសមួយដែលបានចូលទៅក្នុងអង្គការសហប្រជាជាតិ ។ យើងចូលអាស៊ាននិងយើងអង្គការសហប្រជាជាតិតាំងពីឆ្នាំ៥០ជាង |

ណាស់ ហើយចឹងទៅមានច្បាប់មួយចំនួនគេហាមប្រាមមិនឲ្យរំលោភសិទ្ធមនុស្សឬក៏សម្លាប់មនុស្ស ។

ហានៈ បាទ ។

វណ្ណៈ ប៉ុន្តែថៃដន្យយើងមិនដឹងថាយ៉ាងម៉េចនៅក្នុងសម័យខ្មែរក្រហម នៅក្នុងសម័យខ្មែរក្រហមអ្នកខ្លះក៏បានស្រួលទៅមិនមានការហូបចុកពិបាកទេ ប៉ុន្តែមានប្រជាជនមួយចំនួនត្រូវបានគេសម្លាប់និងហូបចុកមិនឆ្អែត ដល់ពេលនៅក្នុងសម័យខ្មែរក្រហមហ្នឹងដូចថា ប៉ុល ពតគាត់សម្លាប់ហើយ តែប៉ុល ពត លោក តា អៀង សារី លោកតា នួន ជា លោកតា ខៀវ សំផន និងអៀង ធិរិទ្ធអីហ្នឹងនៅក្នុងថ្នាក់មេដឹកនាំជាន់ខ្ពស់ ។

ហានៈ បាទ ។

វណ្ណៈ ចឹងនៅសម័យគាត់ដឹកនាំហ្នឹង អង្គការសម័យប្រជាជាតិមើលឃើញថា ប្រជាជនរងគ្រោះស្លាប់ជាងមួយលាននាក់ ។

ហានៈ បាទ ។

វណ្ណៈ ចឹងគាត់ត្រូវតែប្រឈរមុខនិងផ្លូវច្បាប់ ចឹងនៅពេលកាត់ទោសហ្នឹងគាត់និយាយឲ្យអស់ទៅមកពីមូលហេតុចេះៗឲ្យឃើញសខ្មៅក៏វាល្អដែរ ដើម្បីឲ្យអន្តរជាតិដឹងនិងប្រជាជនបានដឹងថាមកពីមូលហេតុអីណាពូ ។

ហានៈ បាទ ។

វណ្ណៈ បាទ!ចឹងយើងក៏មិនទាន់បានដឹងថា ពីណានៅក្រោយពីខាងណាក៏យើងមិនដឹងដែរ ចឹងបានជាគេកាត់ទោសខុចមួយនេះ ឌុចបានឆ្លើយថាគាត់សម្លាប់តាមថ្នាក់លើបញ្ជាមកទេ?

ហានៈ បាទ ។

វណ្ណៈ គាត់មិនមែនសម្លាប់ដោយចិត្តឯងទេ ប៉ុន្តែមនុស្សដែលគាត់សម្លាប់ហ្នឹងជាងមួយម៉ឺននាក់ដែលគាត់បានបញ្ជាឲ្យកូនចៅគាត់សម្លាប់ទៀតនៅក្នុងគុកទួលស្លែង ។

ហានៈ បាទ ។

វណ្ណៈ អាហ្នឹងឯកសារមានជាងមួយម៉ឺនហ្នឹង ហ្នឹងជាឯកសារដែលនៅសល់ក្នុងសៀវភៅ តាមពិតទៅមនុស្សច្រើនជាងហ្នឹងទៀតដែលត្រូវស្លាប់ ។

ហានៈ ស្លាប់ច្រើនជាងហ្នឹងទៀតដែលយើងចងក្រងវាមិនបានអស់ ។

វណ្ណៈ បាទ!ចឹងបើយើងដាក់ថាស្លាប់នៅហ្នឹងប្រើមេធាវីឌុច ឌុចក៏ប្រកែកដែរ ដោយសារគ្មានភស្តុតាំងឲ្យគាត់មើល ស្លាប់ជាងមួយម៉ឺនហ្នឹងមានសៀវភៅក្រាំងឈ្មោះដែលនៅសល់រាល់ថ្ងៃ ។

ហានៈ បាទ ។

វណ្ណៈ ចឹងបើសិនជាគាត់ប្រកែកថា ដាងមួយម៉ឺនខុសយើងហុចសៀវភៅឲ្យគាត់មើល ។

ហានៈ បាទ ។

វណ្ណៈ ដូចជាក្នុងសៀវភៅហ្នឹងមានឈ្មោះ «ក» ឈ្មោះ «ខ» ចឹងដាក់ថាកំទេចនៅថ្ងៃនេះខែនេះចឹងមានទាំងអស់ចឹងគាត់អត់មានប្រកែកបានទេ ។

ហានៈ បាទ ។

វណ្ណៈ ប៉ុន្តែនៅសល់មេដឹកនាំខ្មែរក្រហមប៉ុន្មាននាក់ទៀតហ្នឹង បួននាក់ទៀតហ្នឹងត្រូវបានកាត់ទោសក្នុងឆ្នាំហ្នឹងដែលប្រហែលខែប៉ុន្មានច្បាស់លាស់ទេពូ ។

ហានៈ បាទ ។

វណ្ណៈ ចឹងពូមានយល់ឃើញយ៉ាងម៉េចដែលរឿងការកាត់ទោសហ្នឹងពូ បើតាមពូគិត អានេះជារឿងពូគិតដោយខ្លួនឯងអត់មានថាខុសត្រូវអីទេ ពូនិយាយទៅខ្លាចបេះខ្លាចចុះអត់ទេ អត់មានត្រូវខ្លាចថា បេះចុះទេ ព្រោះឥឡូវគេមានសិទ្ធមនុស្សគេមិនបេះតែចាប់មនុស្ស មិនបេះតែគំរាមមនុស្សបានទេ ព្រោះស្រុកយើងចាត់ទុកថាជាស្រុកសេរីប្រជាធិបតេយ្យដែរណាស់?

ហានៈ បាទ ។

វណ្ណៈ ចឹងបើតាមគំនិតពូ ពូគិតថាកាត់ទោសអ្នកបួននាក់ហ្នឹង ពូយល់ឃើញយ៉ាងម៉េចថា កាត់ទាសខុសឬក៏វាត្រូវឬក៏យ៉ាងម៉េចពូគិត ពូអាចពិចារណាបានទេ?

ហានៈ ខ្ញុំត្រង់ហ្នឹងដូចជារឿងពិបាកនិយាយដែរ និយាយទៅវាប៉ះពាល់ផ្នែកខាងនយោបាយ ។

វណ្ណៈ បាទ ។

ហានៈ ខ្ញុំនិយាយតែប៉ុណ្ណឹងអស់លោកយល់ហើយ ។

វណ្ណៈ បាទ!ចឹងខ្ញុំចង់ជំរាបសួរមួយទៀត សព្វថ្ងៃនេះមេធាវីខាងខ្មែរយើងមិនឲ្យកាត់តទៀតទេតែសហមេធាវីបរទេសទៀមទាកាត់០០៣និង០០៤ពូមានដែលស្តាប់វិទ្យុទេ?

ហានៈ អត់មានវិទ្យុស្តាប់ផង ។

វណ្ណៈ បាទ!ដូចជាគេចង់ចាប់មនុស្សបន្ថែម៥នាក់ទៀត បើចិត្តពូ ពូគាំទ្រឬមិនគាំទ្រទេ?

ហានៈ ចង់ចាប់ខ្មែរក្រហមមេដឹកនាំចាស់ឬចង់ចាប់ពីណាមួយ?

វណ្ណៈ ចាប់ហ្នឹងបើតាមការគិតហ្នឹងយើងមិនដឹងជាចាប់ពីណាទេ តែគ្រាន់គេចាប់ចាប់និងជាប្រធានតំបន់ឬជាគណៈស្រុកសម័យខ្មែរក្រហម៥នាក់ទៀតអីចឹង?

ហនៈ បាទ ។

វណ្ណៈ ចឹងពូមានការគាំទ្រឲ្យចាប់ឬចិត្តពូថាប៉ុណ្ណឹងបានហើយមិនបាច់ចាប់ទៀតទេ?

ហនៈ តាមចិត្តខ្ញុំ ខ្ញុំថាបញ្ចប់មិនបាច់ចាប់អីតទៅទៀតទេ សម័យនេះហើយ«ប្រពន្ធគាត់និយាយថាខ្មែរគ្នាឯងសោះ» វវល់ខ្មែរចាប់ខ្មែរផាប់ហើយ ។

វណ្ណៈ បាទ!ចឹងខ្ញុំអរគុណពូច្រើនហើយ ។

ហនៈ បាទ ។

**ចប់**